កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន

មាតិកា

កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន 3

ឧបសម្ព័ន្ធ ឃ៖ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន នៃ ក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់ក្រុប ម.ក 16

កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរមូលបត្រនៅលើផ្ទាំងជួញដូររបស់ ផ.ម.ក 17

កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរមូលបត្រនៅលើផ្ទាំងពាណិជ្ជករមូលបត្រកម្ពុជា 25

កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរមូលបត្ររដ្ឋនៅលើផ្លេតហ្វម NBC 32

តារាង ក៖ និយមន័យ និងពាក្យកាត់ 40

តារាង ខ៖ គោលការណ៍ឯកជនភាព 41

តារាង គ៖ បញ្ជីឈ្មោះក្រុមហ៊ុន រ៉ូយ៉ាល់ក្រុប 42

កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន

បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦

កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ (“**កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន**”) ត្រូវបានធ្វើឡើងរវាងក្រុមហ៊ុន និងលោកអ្នក នៅកាលបរិច្ឆេទទទួលយក។

ប្រការ ១៖ ការបង្កើតកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន

លុះត្រាតែមានការចែងផ្ទុយពីនេះ៖

(១) ការយោងទៅលើភេទប្រុស មានន័យរួមបញ្ចូលទាំងភេទស្រី និងអភេទផងដែរ ហើយផ្ទុយមកវិញ ហើយការយោងទៅលើឯកវចនៈ មានន័យរួមបញ្ចូលទាំងពហុវចនៈផងដែរ។

(២) ចំណងជើងនៃប្រការ និងប្រការរង ដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបញ្ចូលដើម្បីភាពងាយស្រួលប៉ុណ្ណោះ និងមិនមានន័យជាការបកស្រាយ ការកំណត់ ឬការពិពណ៌នាអំពីវិសាលភាពនៃកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន ឬគោលបំណងនៃបញ្ញត្តិដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះឡើយ។

(៣) កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ ត្រូវប្រើប្រាស់ជាការព្រមព្រៀងគោល។ រាល់កិច្ចព្រមព្រៀអតិថិជនទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ និងតារាងនីមួយៗ នៃកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន នេះ ត្រូវបានយកមកអាន និងបកស្រាយថាជាផ្នែកសំខាន់ និងជាផ្នែកមួយនៃកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។

(៤) ក្នុងករណីមានភាពមិនស្របគ្នា ឬខុសគ្នារវាងបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ និងកិច្ចព្រមព្រៀងជាក់លាក់ណាមួយ ឬឯកសារពាក់ព័ន្ធផ្សេងទៀត បញ្ញត្តិដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះនឹងមានអាទិភាព លើកលែងតែបានចែងយ៉ាងច្បាស់ផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងជាក់លាក់ និងឬឯកសារពាក់ព័ន្ធផ្សេងទៀតនោះ។

(៥) ក្នុងករណីមានភាពមិនស្របគ្នា ឬ ខុសគ្នារវាងបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ និងឧបសម្ព័ន្ធណាមួយ នោះបញ្ញត្តិដែលមានចែងនៅក្នុងឧបសម្ព័ន្ធនោះ នឹងមានអាទិភាពលើកលែងតែមានការចែងផ្សេងពីនេះ។

ប្រការ ២៖ គោលបំណង, វិសាលភាព និងកម្មវិធី

២.១ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ បង្កើតបានជាកិច្ចព្រមព្រៀងចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលធ្វើឡើងរវាងលោកអ្នក (“**លោកអ្នក**” ឬ “**របស់លោកអ្នក**”) និងក្រុមហ៊ុនពាក់ព័ន្ធ ដូចខាងក្រោម៖

(១) **Wing Bank (Cambodia) Plc. (“Wing Bank”)** – សេវាធនាគារ និងហិរញ្ញវត្ថុ

(២) **Royal Group Funds Co., Ltd. (“RGF”)** – មូលនិធិ និងគម្រោងវិនិយោគរួម

(៣) **Royal Group Exchange (RGX) Co., Ltd. (“RGX”)** – សេវាកម្មជួញដូរទ្រព្យឌីជីថល

(៤) **Royal Group Securities Plc. (“RGS”)** – សេវាជួញដូរមូលបត្រ និងវិនិយោគ

ព័ត៌មានលម្អិតរបស់ក្រុមហ៊ុនមានចែងនៅក្នុងតារាង គ “បញ្ជីរាយនាមក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប”។

(តទៅនេះហៅ ដោយឡែកពីគ្នាថា “**ក្រុមហ៊ុន**” និង រួមគ្នាថា “**ក្រុមហ៊ុននីមួយៗ**”)

២.២ សម្រាប់ការទទួលយក កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ លោកអ្នកយល់ព្រមថា ក្រុមហ៊ុនផ្តល់ផលិតផល និងសេវាកម្ម របស់ខ្លួនដោយឯករាជ្យ ក្រោមអាជ្ញាប័ណ្ណអាជីវកម្ម កាតព្វកិច្ចផ្លូវច្បាប់ និងកិច្ចព្រមព្រៀងអតិថិជនរៀងខ្លួន។

២.៣ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ អនុវត្តនៅពេលដែលលោកអ្នកជាវ (Subscribe) ផលិតផល ឬសេវាកម្មជាក់លាក់ណាមួយ របស់ក្រុមហ៊ុន។ នៅពេលដំណើរការផលិតផល ឬសេវាកម្មណាមួយ កិច្ចព្រមព្រៀងអតិថិជននៃផលិតផលជាក់លាក់របស់ក្រុមហ៊ុន នោះ ដូចដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ នឹងត្រូវមានអនុភាពអនុវត្ត បន្ថែមជាមួយនឹង កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ ។

ប្រការ ៣៖ តួនាទីឯករាជ្យរបស់ក្រុមហ៊ុននីមួយៗ និងការទទួលខុសត្រូវ

៣.១ ក្រុមហ៊ុននីមួយៗ គឺជានីតិបុគ្គលដាច់ដោយឡែក ដែលបានចុះបញ្ជីក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការផ្តល់ផលិតផល និងសេវាកម្មរបស់ខ្លួនដោយឯករាជ្យ។ ក្រុមហ៊ុនទាំងនេះ មិនមានតួនាទីជាភ្នាក់ងារ មិនតំណាង មិនជានា ឬមិនផ្តល់ផលិតផល និងសេវាកម្មជំនួសឱ្យក្រុមហ៊ុនដទៃទេ លុះត្រាតែមានការកំណត់ជាក់លាក់ក្នុងកិច្ចព្រមព្រៀង ឬការរៀបចំដាច់ដោយឡែក ដោយ អនុលោមតាមច្បាប់កម្ពុជា។ ដើម្បីជៀសវាងការភាន់ច្រឡំ មិនមានក្រុមហ៊ុនណាមួយអាច៖

(១) ផ្តល់ផលិតផល និងសេវាកម្មលើសពីវិសាលភាពនៃសកម្មភាពក្រោមអាជ្ញាប័ណ្ណរបស់ខ្លួនឡើយ

(២) អនុវត្តកាតព្វកិច្ចរបស់ក្រុមហ៊ុនផ្សេង

(៣) ចូលប្រើប្រាស់ ប្រតិបត្តិការ ឬគ្រប់គ្រងសេវាកម្ម និងផលិតផលដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សេង ។

៣.២ ក្រុមហ៊ុននីមួយៗត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះសកម្មភាពក្រោមអាជ្ញាប័ណ្ណដែលខ្លួនកាន់កាប់ រួមបញ្ចូលតែមិនកម្រិតត្រឹមតែ៖

(១) ដំណើរការទទួលអតិថិជនរបស់ខ្លួន

(២) ផលិតផល និងសេវាកម្មរបស់ខ្លួន

(៣) ការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានដែលត្រូវអនុវត្តលើក្រុមហ៊ុននោះ

(៤) ដំណើរការប្រតិបត្តិការ ការចែកចាយ ការអនុវត្ត ការបង្ហាញព័ត៌មាន ការគ្រប់គ្រងថ្លៃសេវា និងថ្លៃឈ្នួល ការគ្រប់គ្រងហានិភ័យ ទំនាក់ទំនងអតិថិជន និងការដោះស្រាយពាក្យបណ្តឹងរបស់អតិថិជន។

៣.៣ ក្រុមហ៊ុនដែលស្ថិតក្រោមកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ មិនទទួលខុសត្រូវចំពោះសកម្មភាព ការអវត្តមាន ការបរាជ័យ ការរំខាន កំហុស ការបាត់បង់ ឬវិវាទណាមួយ ដែលកើតឡើងពីផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនផ្សេងឡើយ។ បញ្ហាដែលពាក់ព័ន្ធនឹងផលិតផល ឬសេវាកម្ម ត្រូវដោះស្រាយដោយផ្ទាល់ជាមួយក្រុមហ៊ុនដែលទទួលបន្ទុកចំពោះផលិតផល ឬសេវាកម្មនោះ។

៣.៤ មិនមានខ្លឹមសារណាមួយ ក្នុងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ ត្រូវបានបកស្រាយថា ជាការរួមបញ្ចូល សមាហរណកម្ម ឬការផ្ទេរសិទ្ធិអាជ្ញាប័ណ្ណ សិទ្ធិប្រតិបត្តិការ ឬសេវាកម្មរបស់ក្រុមហ៊ុនមួយទៅឱ្យក្រុមហ៊ុនមួយទៀតឡើយ។ ក្រុមហ៊ុននីមួយៗ ត្រូវ អនុវត្តសកម្មភាពរបស់ខ្លួនក្នុងកម្រិតវិសាលភាពក្រោមអាជ្ញាប័ណ្ណអាជីវកម្ម និងវិធានដែលខ្លួនមានប៉ុណ្ណោះ។

ប្រការ ៤៖ ការទទួលយក និងការដំណើរការ

៤.១ ការទទួលយកកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន

លោកអ្នកទទួលស្គាល់ថា លោកអ្នកបានអាន យល់ និងយល់ព្រមភ្ជាប់កាតព្វកិច្ច ផ្លូវច្បាប់តាមខចែង និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។ ការទទួលយករបស់លោកអ្នកនឹងមានប្រសិទ្ធភាព តាមរយៈការបញ្ជាក់គ្រប់ទម្រង់ រាប់ទាំងការបញ្ជាក់ដោយការចុះហត្ថលេខាដោយដៃ ឬ តាមប្រព័ន្ធអេឡិចត្រូនិកគ្រប់ប្រភេទ រួមបញ្ចូលតែមិនកម្រិតត្រឹម ការចុចលើប្រអប់

យល់ព្រម (Ticking Box) ការបញ្ចូលលេខកូដ (OTP) ឬលេខកូដសម្ងាត់ (PIN) ការផ្ទៀងផ្ទាត់ជីវមាត្រ (Biometric) ឬវិធីសាស្ត្រផ្ទៀងផ្ទាត់អត្តសញ្ញាណផ្សេងៗទៀត ដែលត្រូវបានកំណត់ឱ្យប្រើប្រាស់តាមវេទិកាពាក់ព័ន្ធ។ លោកអ្នកបានយល់ព្រមយ៉ាងច្បាស់ថា ការទទួលយកតាមប្រព័ន្ធអេឡិកត្រូនិចបែបនេះ បង្កើតជាហត្ថលេខាអេឡិកត្រូនិចដែលមានសុពលភាព ហើយមានអនុភាពផ្លូវច្បាប់គ្រប់គ្រាន់ និងមានប្រសិទ្ធភាពស្មើនឹងហត្ថលេខាចុះដោយដៃ។ លើសពីនេះ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ នឹងមានអនុភាពផ្លូវច្បាប់លើលោកអ្នក ចាប់ពីកាលបរិច្ឆេទទទួលយក រហូតដល់កម្រិតអតិបរមាតាមការតម្រូវដោយច្បាប់បទប្បញ្ញត្តិ ឬវិធានជាធរមាន។

៤.២ ការទទួលយកតែមួយដង និងការអនុវត្តបន្ត

លោកអ្នកតម្រូវឱ្យទទួលយក កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ តែមួយដងគត់ មុនពេលប្រើប្រាស់ ឬស្នើសុំផលិតផល ឬសេវាកម្មណាមួយពីក្រុមហ៊ុនណាមួយក្នុងចំណោមក្រុមហ៊ុនទាំងនេះ។ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននៃក្រុមហ៊ុននេះ នឹងចាប់ផ្តើមមានមានសុពលភាពចាប់ពីកាលបរិច្ឆេទទទួលយក (“**កាលបរិច្ឆេទទទួលយក**”) របស់លោកអ្នក និងបន្តរហូតដល់ លោកអ្នកមានទំនាក់ទំនងជាមួយក្រុមហ៊ុននីមួយៗ លុះត្រាតែបានបញ្ចប់តាមខចែង និងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

៤.៣ ការដំណើរការផលិតផល និងសេវាកម្ម

ស្របតាមគោលបំណងនៃ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ “**ការដំណើរការ**” (Activation) គឺសំដៅលើសកម្មភាពណាមួយដែលលោកអ្នកធ្វើ ដើម្បីចូលរួម ជាវ (Subscribe) ចុះឈ្មោះ ដាក់ពាក្យ ឬស្នើសុំផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនណាមួយ។ ការដំណើរការនេះ រួមបញ្ចូលតែមិនកម្រិតត្រឹម ការដាក់ពាក្យស្នើសុំ ការចាប់ផ្តើមប្រតិបត្តិការ ការដាក់បញ្ជាទិញការវិនិយោគ ការបើកគណនី ឬសកម្មភាពស្រដៀងគ្នាណាមួយ ដែលត្រូវការ ការផ្ទៀងផ្ទាត់អត្តសញ្ញាណតាមរយៈ ការបញ្ចូលលេខកូដ (OTP) ឬលេខកូដសម្ងាត់ (PIN) ឬវិធីសាស្ត្រផ្ទៀងផ្ទាត់ផ្សេងៗទៀត។

៤.៤ អនុភាពនៃ ឧបសម្ព័ន្ធ (Annexes) ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអតិថិជននៃផលិតផលជាក់លាក់ (Product-Specific Customer Agreements)

នៅពេលដែលលោកអ្នកដំណើរការ (Activation) ផលិតផល ឬសេវាកម្មណាមួយ លោកអ្នកត្រូវបានចាត់ទុកថា បានទទួលយកកិច្ចព្រមព្រៀងអតិថិជននៃផលិតផលជាក់លាក់នោះ ក្រោមឧបសម្ព័ន្ធ (Annex) នៃផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុននោះ ដោយមិនតម្រូវឲ្យមានការបញ្ជាក់ ឬចុះហត្ថលេខាបន្ថែមទៀតឡើយ លុះត្រាតែមានការទាមទាជាក់លាក់សម្រាប់ផលិតផល និងសេវាកម្មនោះ។ ដើម្បីជៀសវាងការភាន់ច្រឡំ កិច្ចព្រមព្រៀងអតិថិជន ក្រោមឧបសម្ព័ន្ធ (Annex) នីមួយៗ នឹងមានសុពលភាពនៅពេលដំណើរការ(Activation) ហើយនិងគ្រប់គ្រងសិទ្ធិ កាតព្វកិច្ច និងហានិភ័យរបស់លោកអ្នកពាក់ព័ន្ធនឹងផលិតផល ឬសេវាកម្មនោះជាមួយក្រុមហ៊ុនពាក់ព័ន្ធ។

៤.៥ ឯករាជ្យភាពនៃការដំណើរការផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុននីមួយៗ

ការដំណើរការ (Activation) ផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនណាមួយ មិនត្រូវបានចាត់ទុកថា ជាការដំណើរការ ឬការទទួលយកកាតព្វកិច្ចលើផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនផ្សេងទៀតឡើយ។ ក្រុមហ៊ុននីមួយៗត្រូវទទួលខុសត្រូវទាំងស្រុងលើការទទួលយកអតិថិជន (Onboarding) ការផ្តល់សេវា និងការអនុលោមតាមច្បាប់ សម្រាប់ផលិតផល និងសេវាកម្មរបស់ខ្លួន។

៤.៦ លក្ខខណ្ឌបន្ថែមនៅពេលដំណើរការ (ប្រសិនបើមាន)

ផលិតផល ឬសេវាកម្មមួយចំនួន អាចតម្រូវឱ្យលោកអ្នកទទួលយកលក្ខខណ្ឌបន្ថែមនៅកំឡុងពេលដំណើរការ (Activation)។ ក្នុងករណីនេះ លក្ខខណ្ឌបន្ថែមទាំងនេះ នឹងអនុវត្តតែចំពោះផលិតផល ឬសេវាកម្មពាក់ព័ន្ធតែប៉ុណ្ណោះ ហើយមិនត្រូវបានពង្រីកវិសាលភាពនៃការអនុវត្តទៅលើផលិតផល ឬសេវាកម្មផ្សេងទៀតដែលផ្តល់ដោយក្រុមហ៊ុនផ្សេងទៀតឡើយ។

ប្រការ ៥៖ ថ្លៃសេវា ថ្លៃឈ្នួល និងការទូទាត់

៥.១ ក្រុមហ៊ុននីមួយៗមានរចនាសម្ព័ន្ធថ្លៃសេវា ពន្ធ កម្រៃជើងសារ និងគំរូតម្លៃផ្ទាល់ខ្លួន។

៥.២ ថ្លៃសេវាដែលត្រូវបង់ឱ្យក្រុមហ៊ុនមួយ មិនអាចផ្ទេរ ឬប្រើប្រាស់ឆ្លងទៅក្រុមហ៊ុនមួយទៀតបានទេ។

ប្រការ ៦៖ ការយល់ព្រមរបស់លោកអ្នក

៦.១ ការយល់ព្រមសម្រាប់ការចែករំលែកទិន្នន័យឯកជន

តាមរយៈការទទួលយកកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ លោកអ្នកអនុញ្ញាតយ៉ាងជាក់ច្បាស់ និងយល់ព្រមឲ្យក្រុមហ៊ុនប្រមូលទិន្នន័យ រក្សាទុក និងបង្ហាញទិន្នន័យឯកជនរបស់លោកអ្នកទៅកាន់បុគ្គលដូចខាងក្រោម ដោយអនុលោមតាមច្បាប់ជាធរមាន និងតាមគោលការណ៍ឯកជនភាពរបស់យើង៖

(១) បុគ្គលិក និងភ្នាក់ងាររបស់យើង ក្នុងកម្រិតដែលចាំបាច់និងសមហេតុផលសម្រាប់ការអនុវត្តការងារទៅតាមផលិតផល និងសេវាកម្ម ដែលលោកអ្នកបានស្នើសុំ ដែលក្នុងករណីនេះ យើងនឹងតម្រូវឲ្យបុគ្គលទាំងនោះ គោរពតាមគោលការណ៍ឯកជនភាពដែលភ្ជាប់មកជាមួយកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។

(២) ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើង ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប សម្រាប់គោលបំណង លក់ផលិតផល និងសេវាកម្មទៅវិញទៅមក ដែលក្នុងករណីនេះ យើងនឹងតម្រូវឲ្យក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងនោះ គោរពតាមគោលការណ៍ឯកជនភាពរបស់យើង។ យើងខ្ញុំនឹងចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកទៅកាន់ក្រុមហ៊ុនណាមួយខាងលើ តែក្នុងករណី និងនៅពេលដែល លោកអ្នកស្នើសុំ ដាក់ឲ្យដំណើរការ (Activation) ជាវ (Subscribe) ឬប្រើប្រាស់ផលិតផល ឬសេវាកម្មមួយ ឬច្រើនរបស់ក្រុមហ៊ុននោះ។

(៣) អ្នកផ្គត់ផ្គង់ ទីប្រឹក្សា អ្នកអនុវត្តគម្រោងបន្ត និងអ្នកផ្តល់សេវាកម្ម ដែលត្រូវការចូលប្រើទិន្នន័យ និងព័ត៌មាន ដើម្បីអនុវត្តដំណើរការ ឬប្រតិបត្តិការ ក្នុងនាមក្រុមហ៊ុន សម្រាប់គោលបំណងអភិវឌ្ឍផលិតផល ដែលក្នុងករណីនេះ យើងនឹងទាមទារឲ្យបុគ្គលទាំងនោះ គោរពតាមគោលការណ៍ឯកជនភាពដែលភ្ជាប់មកជាមួយកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។

(៤) ក្នុងការឆ្លើយតបនឹងសំណើសុំទិន្នន័យពីលោកអ្នក ប្រសិនបើក្រុមហ៊ុនជឿថា ការបង្ហាញទិន្នន័យគឺស្របតាមច្បាប់ បទប្បញ្ញត្តិ ឬដំណើរការផ្លូវច្បាប់ណាមួយ (ឧទាហរណ៍ ដើម្បីបង្កើត ប្រើប្រាស់ ឬការពារសិទ្ធិស្របច្បាប់របស់យើង ដូចជាសម្រាប់ការពារពីការឆបោក ឬគៃបន្លំ) ឬតាមការតម្រូវរបស់ច្បាប់ បទប្បញ្ញត្តិ ឬវិធានជាធរមាន។

(៥) ពាក់ព័ន្ធនឹងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញលក់ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងក្រុមហ៊ុន ការលក់ចំណែកណាមួយ ឬទាំងស្រុងនៃអាជីវកម្ម ឬទ្រព្យសម្បត្តិក្រុមហ៊ុន ទៅឲ្យបុគ្គលផ្សេងទៀត ឬប្រតិបត្តិការស្រដៀងគ្នានេះ។

(៦) តុលាការមានសមត្ថកិច្ច វេទិកាដោះស្រាយវិវាទ ឬនិយ័តករ ដោយការស្នើសុំ ឬដើម្បីបំពេញកាតព្វកិច្ចបង្ហាញព័ត៌មាន ឬការរាយការណ៍ ដែលតម្រូវដោយច្បាប់។

សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីការការពារទិន្នន័យឯកជន លោកអ្នកយល់ព្រម អនុលោមតាមគោលការណ៍ឯកជនភាពដែលភ្ជាប់មកជាមួយកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។

៦.២ ការយល់ព្រមសម្រាប់ការបង្កកសមតុល្យ ឬគណនី

លោកអ្នកអនុញ្ញាត និងយល់ព្រមឲ្យក្រុមហ៊ុនពាក់ព័ន្ធ ផ្អាក រឹតបន្តឹង ឬបង្កកគណនី ឬមូលនិធិណាមួយរបស់លោកអ្នក ដោយមិនចាំបាច់ជូនដំណឹងជាមុន ក្នុងករណីដូចខាងក្រោម៖

(១) លោកអ្នកទទួលប្រាក់ ដែលលោកអ្នកមិនគួរទទួលបាន ដោយកំហុសប្រព័ន្ធ ការទូទាត់ស្នួន ការគៃបន្លំ ឬព្រឹត្តិការណ៍ដែលមិនបានព្រៀងទុកផ្សេងទៀត និងមិនមែនជាកម្មសិទ្ធិរបស់លោកអ្នក។

(២) មានការជឿជាក់ ឬសង្ស័យថា គណនីរបស់លោកអ្នកមានការជាប់សង្ស័យ ឬជាប់ពាក់ព័ន្ធ ឬធ្លាប់ពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ឬសកម្មភាពឧក្រិដ្ឋនានា។

(៣) ក្រុមហ៊ុនទទួលបានសេចក្តីបង្គាប់ពីតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបង្កកសមតុល្យ ឬគណនីរបស់លោកអ្នក។ និង

(៤) ករណីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការខូចខាត ឬការបាត់បង់ណាមួយ ដែលកើតឡើងពីការផ្អាក ឬការបង្កកសមតុល្យ ឬគណនីដែលអនុវត្តដោយភាពស្មោះត្រង់ និងអនុលោមតាមច្បាប់ជាធរមាន។

៦.៣ ការយល់ព្រមឲ្យបង្វិលទឹកប្រាក់ត្រឡប់មកវិញ

លោកអ្នកអនុញ្ញាតឲ្យក្រុមហ៊ុនបង្វិលទឹកប្រាក់ត្រឡប់មកវិញ សម្រាប់ប្រតិបត្តិការណាមួយដែលបានបញ្ចូលទឹកប្រាក់ចូលក្នុងគណនីរបស់លោកអ្នកដោយសារតែបញ្ហាបច្ចេកទេស កំហុសប្រព័ន្ធ កំហុសដែលបង្កឡើងដោយមនុស្ស ដំណើរការស្នួន ការគៃបន្លំ ឬព្រឹត្តិការណ៍ ដែលមិនបានព្រៀងទុកផ្សេងទៀត ដែលស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីដែលសមតុល្យក្នុងគណនីមិនគ្រប់គ្រាន់សម្រាប់ការបង្វិលទឹកប្រាក់ត្រឡប់មកវិញ លោកអ្នកយល់ព្រមទូទាត់ប្រាក់ដែលជំពាក់ភ្លាមៗ បន្ទាប់ពីទទួលបានការជូនដំណឹង។ ក្រុមហ៊ុនរក្សាសិទ្ធិចាត់វិធានការផ្លូវច្បាប់ ឬរាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធប្រសិន បើការទូទាត់ប្រាក់នោះមិនបានធ្វើឡើងទាន់ពេលវេលា។

ក្នុងករណីមិនមានការព្រមព្រៀងទាក់ទងនឹងការកែតម្រូវ លោកអ្នកអាចដាក់ពាក្យបណ្តឹងជាផ្លូវការ តាមរយៈដំណើរការដោះស្រាយបណ្តឹងផ្ទៃក្នុងរបស់ក្រុមហ៊ុន។ គ្មានអ្វីនៅក្នុងប្រការនេះអាចប៉ះពាល់សិទ្ធិរបស់លោកអ្នក ក្នុងការបញ្ជូនវិវាទដែលមិនទាន់បានដោះស្រាយទៅកាន់អាជ្ញាធរមានសត្ថកិច្ច ឬតុលាការ ដោយអនុលោមតាមច្បាប់ជាធរមាន។

៦.៤ ការយល់ព្រមសម្រាប់ឥណពន្ធដោយផ្ទាល់

លោកអ្នកអនុញ្ញាត និងយល់ព្រមឲ្យក្រុមហ៊ុនកាត់ ឬដកយកទឹកប្រាក់ដោយស្វ័យប្រវត្តិចេញពីគណនីដែលលោកអ្នកបានកំណត់ទុកជាមុន ឬគណនីណាមួយរបស់លោកអ្នក ដែលមាននៅក្រុមហ៊ុន ដោយមិនចាំបាច់ជូនដំណឹង ឬទទួលបានការយល់ព្រមបន្ថែមពីលោកអ្នក ដើម្បីអនុវត្តកាតព្វកិច្ចដែលលោកអ្នកបានយល់ព្រម នៅពេលទទួលយកកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន ឬកិច្ចព្រមព្រៀងអតិថិជននៃផលិតផលជាក់លាក់នេះ រួមមានការទូទាត់លើប្រាក់ដើម ការប្រាក់ ថ្លៃសេវា ថ្លៃឈ្នួល ថ្លៃសេវាធានារ៉ាប់រង និងចំនួនផ្សេងទៀតដែលត្រូវបង់ទៅឲ្យក្រុមហ៊ុន ដោយអនុលោមតាមច្បាប់ជាធរមាន។

ប្រការ ៧៖ ការយកចិត្តទុកដាក់ស្គាល់អតិថិជន (“KYC”)

៧.១ លោកអ្នកទទួលស្គាល់ថា លោកអ្នកត្រូវតែផ្តល់ព័ត៌មាន និងឯកសារដែលចាំបាច់សម្រាប់ការកំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជន អនុលោមតាមច្បាប់ជាធរមាន។ “ការយកចិត្តទុកដាក់ស្គាល់អតិថិជន” (“KYC”) ដំបូងនឹងត្រូវធ្វើឡើងនៅពេលមានការចូលរួមរបស់អតិថិជន (Onboarding) ហើយព័ត៌មាន “ការយកចិត្តទុកដាក់ស្គាល់អតិថិជន” (“KYC”) នឹងត្រូវបានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាប្រចាំអំឡុងពេលទំនាក់ទំនងរបស់លោកអ្នកជាមួយក្រុមហ៊ុន។

៧.២ ក្រុមហ៊ុននឹងស្នើសុំការបញ្ជាក់របស់លោកអ្នក រាល់ពេលធ្វើបច្ចុប្បន្នភាព ឬកែប្រែព័ត៌មាន “ការយកចិត្តទុកដាក់ស្គាល់អតិថិជន” (“KYC”) របស់លោកអ្នកតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈបណ្តាញឌីជីថល (Digital Channels) រួមមាន កម្មវិធីទូរស័ព្ទដៃ (Mobile Applications), សារជូនដំណឹងអេឡិចត្រូនិក (Electronic Notifications) ឬវេទិកាផ្សេងៗទៀត។ លោកអ្នកត្រូវពិនិត្យ និងបញ្ជាក់ ឬធ្វើបច្ចុប្បន្នភាពភ្លាមៗនៅពេលមានសំណើ។

៧.៣ លោកអ្នកត្រូវជូនដំណឹងដល់ក្រុមហ៊ុនភ្លាមៗអំពីការផ្លាស់ប្តូរព័ត៌មាន ឬកាលៈទេសៈណាមួយ ដែលអាចនាំឲ្យព័ត៌មាន សេចក្តីថ្លែងការណ៍ ការអះអាង និងព័ត៌មានជាក់លាក់ណាមួយ ដែលលោកអ្នកបានផ្តល់ជូនក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ ឬមិនពិតប្រាកដក្នុងពេលណាមួយ។

៧.៤ លោកអ្នកអនុញ្ញាត ឱ្យក្រុមហ៊ុនធ្វើការប្រមូល ប្រើប្រាស់ និងដំណើរការទិន្នន័យជីវមាត្រ (biometric data) រួមបញ្ចូលតែមិនកម្រិតត្រឹម បច្ចេកវិទ្យាផ្ទៀងផ្ទាត់មុខ (facial recognition) ឬបច្ចេកវិទ្យាដែលស្រដៀងនឹងនេះ សម្រាប់គោលបំណងក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណ ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ការការពារការក្លែងបន្លំ និងការអនុលោមតាមច្បាប់ជាធរមាន។

៧.៥ ក្នុងករណីដែលក្រុមហ៊ុនមានមូលហេតុសមហេតុផលក្នុងការជឿជាក់ថា ព័ត៌មានណាមួយដែលបានផ្តល់មានភាពមិនត្រឹមត្រូវ អស់សុពលភាព ឬមិនគ្រប់គ្រាន់ លោកអ្នកអនុញ្ញាតឱ្យក្រុមហ៊ុនផ្ទៀងផ្ទាត់ព័ត៌មាននោះពីប្រភពត្រឹមត្រូវតាមច្បាប់ និងធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីកំណត់ត្រារបស់ខ្លួនតាមដែលចាំបាច់ ដើម្បីអនុលោមតាមច្បាប់ជាធរមាន។

៧.៦ លោកអ្នកទទួលស្គាល់ថា ផលិតផល និងសេវាកម្មផ្សេងៗ ត្រូវការព័ត៌មាន “ការយកចិត្តទុកដាក់ស្គាល់អតិថិជន” (“KYC”) ខុសៗគ្នាទៅតាមវិសាលភាពនៃផលិតផល និងសេវាកម្មនីមួយៗ។ ការធ្វើ “ការយកចិត្តទុកដាក់ស្គាល់អតិថិជន” (“KYC”) អប្បបរមាដែលផ្អែកលើការកំណត់អត្តសញ្ញាណ នឹងអនុវត្តក្រោមកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។ ព័ត៌មាន “ការយកចិត្តទុកដាក់ស្គាល់អតិថិជន” (“KYC”) បន្ថែម ឬការកែលម្អណាមួយសម្រាប់ផលិតផល ឬសេវាកម្មជាក់លាក់ អាចត្រូវបានស្នើសុំ និងបញ្ជាក់តាមប្រព័ន្ធអេឡិចត្រូនិកនៅពេលដំណើរការផលិតផល ឬតាមតម្រូវការដែលបានកំណត់។

៧.៧ ការបរាជ័យក្នុងការផ្តល់ ឬធ្វើបច្ចុប្បន្នភាពព័ត៌មាន “ការយកចិត្តទុកដាក់ស្គាល់អតិថិជន” (“KYC”) ឬការផ្តល់ព័ត៌មានមិនពិត ក្លែងបន្លំ ឬមិនពេញលេញ មិនថាជាចេតនា ឬដោយការធ្វេសប្រហែស ក្រុមហ៊ុននឹងបដិសេធទៅលើពាក្យស្នើសុំ ការផ្អាក ឬការបញ្ចប់សេវាកម្ម និងអាចបង្កើតឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី (ស៊ីវិល) និង/ឬព្រហ្មទណ្ឌ ក្រោមច្បាប់កម្ពុជាជាធរមាន។

ប្រការ ៨៖ ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងការគ្រប់គ្រងលើទណ្ឌកម្ម

៨.១ លោកអ្នកយល់ព្រម អនុលោមតាមច្បាប់ បទបញ្ជា សេចក្តីណែនាំ និងគោលការណ៍ផ្នែកក្នុងទាំងអស់ ដែលទាក់ទងនឹងច្បាប់ប្រឆាំងការសម្អាតប្រាក់ (AML) ហិរញ្ញប្បទានភេរវកម្ម (CFT) និងទណ្ឌកម្ម (Sanctions) ដូចដែលទាមទារដោយក្រុមហ៊ុននីមួយៗ នៅក្រោមក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប។ ក្រុមហ៊ុននីមួយៗត្រូវអនុលោមតាមច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិជាធរមាន រួមមាន ច្បាប់ប្រឆាំងនឹងការសម្អាតប្រាក់ (AML) ការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម (CFT) និងទណ្ឌកម្ម (Sanctions)។

៨.២ ក្រុមហ៊ុននីមួយៗរក្សាសិទ្ធិក្នុងការសម្រេចចិត្ត ដោយអនុលោមតាមច្បាប់ប្រឆាំងនឹងការសម្អាតប្រាក់ (AML) ការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម (CFT) និងទណ្ឌកម្ម (Sanctions) ក្នុងការពន្យារពេល ទប់ស្កាត់ បង្កក ផ្អាក ឬបដិសេធមិនអនុវត្តប្រតិបត្តិការ ឬក៏ដាក់កម្រិត ឬបញ្ឈប់ការផ្តល់សេវាកម្ម ដោយមិនទទួលខុសត្រូវចំពោះលោកអ្នក បើក្រុមហ៊ុនមានការសង្ស័យថា៖

(១) ប្រតិបត្តិការដែលបំពានច្បាប់ប្រឆាំងនឹងការសម្អាតប្រាក់ (AML) ការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម (CFT) និងទណ្ឌកម្ម (Sanctions)។

(២) ប្រតិបត្តិការដែលពាក់ព័ន្ធ ឬប្រាក់ចំណូលដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ឬការប្រព្រឹត្តខុសច្បាប់។

(៣) សកម្មភាពណាមួយរបស់លោកអ្នក ដែលអាចបង្កឱ្យក្រុមហ៊ុនប្រឈមនឹងហានិភ័យទាក់ទងនឹង ការប្រឆាំងនឹងការសម្អាតប្រាក់ (AML) ការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម (CFT) និងទណ្ឌកម្ម (Sanctions)។

៨.៣ លោកអ្នកត្រូវផ្តល់ព័ត៌មាន និងឯកសារទាំងអស់ដែលស្ថិតនៅក្នុងកាន់កាប់ ការថែរក្សា ឬការគ្រប់គ្រងរបស់លោកអ្នក ដល់ក្រុមហ៊ុនឲ្យបានឆាប់រហ័ស តាមការតម្រូវរបស់ក្រុមហ៊ុន ដើម្បីអនុលោមតាមច្បាប់ និងបទប្បញ្ញតិជាធរមាន ទាក់ទងនឹងការប្រឆាំងនឹងការសម្អាតប្រាក់ (AML) ការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម (CFT) ឬច្បាប់ ឬបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម (Sanctions) ផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។

៨.៤ លោកអ្នកយល់ព្រម និងអនុញ្ញាតឲ្យក្រុមហ៊ុន បង្ហាញព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងលោកអ្នក ឬគណនីរបស់លោកអ្នក ដល់អាជ្ញាធរមានសមត្ថកិច្ចណាមួយ ដែលតម្រូវដោយច្បាប់។

៨.៥ ការបរាជ័យក្នុងការផ្តល់ព័ត៌មាន ឬការមិនអនុវត្តតាមតម្រូវការរបស់ ច្បាប់ប្រឆាំងនឹងការសម្អាតប្រាក់ (AML) ការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម (CFT) និងទណ្ឌកម្ម (Sanctions) ត្រូវបានចាត់ទុកជា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៃ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ ហើយអាចបណ្តាលឱ្យមានការផ្អាក ឬបញ្ឈប់ការផ្តល់សេវាកម្ម។

៨.៦ ក្រុមហ៊ុនណាមួយ ឬភ្នាក់ងារសហការ (Correspondents) របស់ខ្លួននឹងមិនទទួលខុសត្រូវលើការខូចខាតណាមួយដែលកើតឡើងពីការពន្យារពេល ការបដិសេធ ការបង្កក ឬការទប់ស្កាត់ ប្រតិបត្តិការណាមួយ ដែលបានអនុលោមតាមច្បាប់ប្រឆាំងនឹងការសម្អាតប្រាក់ (AML) ការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម (CFT) និងទណ្ឌកម្ម (Sanctions)។

ប្រការ ៩៖ ឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុនក្នុងការកំណត់ប្រតិបត្តិការ

៩.១ ក្រុមហ៊ុនរក្សាសិទ្ធិដើម្បីកំណត់ បដិសេធ ពន្យា ឬលុបចោលប្រតិបត្តិការរបស់លោកអ្នក ដោយមិនមានការជូនដំណឹងជាមុន និងមិនទទួលខុសត្រូវ ប្រសិនបើក្រុមហ៊ុនសង្ស័យថា៖

(១) ការចូលប្រើប្រាស់ប្រព័ន្ធក្រុមហ៊ុន ឈ្មោះអ្នកប្រើប្រាស់ ឬពាក្យសម្ងាត់ អាចបង្កការខាតបង់ដល់លោកអ្នក ឬក្រុមហ៊ុន។

(២) ឯកសារដែលបានបង្ហាញ មិនមានសុពលភាព ឬជាឯកសារក្លែងបន្លំ។

(៣) ប្រព័ន្ធរបស់ក្រុមហ៊ុន ឬឧបករណ៍របស់ក្រុមហ៊ុនមានបញ្ហា ឬមិនអាចប្រើប្រាស់បាន។

(៤) ក្រុមហ៊ុនរកឃើញថា សុវត្ថិភាពគណនីរបស់លោកអ្នក កំពុងស្ថិតក្នុងហានិភ័យ។ ឬ

(៥) ហេតុផលផ្សេងទៀត ដែលក្រុមហ៊ុនត្រូវអនុវត្តអនុលោមទៅតាមច្បាប់។

ប្រការ ១០៖ អត្រាប្តូរប្រាក់ និងការបម្លែងរូបិយប័ណ្ណ

១០.១ ក្នុងប្រតិបត្តិការក្រុមហ៊ុន យើងអាចទទួលប្រាក់ក្នុងប្រភេទរូបិយប័ណ្ណផ្សេងៗគ្នាសម្រាប់ប្រតិបត្តិការ ការទូទាត់ប្រាក់ ការផ្ទេរប្រាក់ ឬការគិតថ្លៃឈ្នួលណាមួយពីគណនីពាក់ព័ន្ធ ក្នុងករណីនេះ ក្រុមហ៊ុននឹងបម្លែងទឹកប្រាក់ក្នុងប្រភេទរូបិយប័ណ្ណផ្សេងៗគ្នា ទៅជារូបិយប័ណ្ណតែមួយនៅក្នុងគណនីរបស់លោកអ្នក ដោយប្រើអត្រាប្តូរប្រាក់លក់រាយដែលក្រុមហ៊ុនផ្តល់នៅថ្ងៃនោះ។ លោកអ្នកទទួល

ស្គាល់ថា អត្រាប្តូរប្រាក់ផ្តល់ជូនដោយក្រុមហ៊ុន អាចផ្លាស់ប្តូរផ្អែកតាមកត្តាមួយចំនួនដូចជា ភាពគ្មានដែនកំណត់ ប្រភេទរូបិយបណ្ណ សម្រាប់ប្រតិបត្តិការ បណ្តាញ (channel) ដែលបានប្រើប្រាស់ ចំនួនប្រតិបត្តិការ រូបិយប័ណ្ណដែលពាក់ព័ន្ធ ពេលវេលានៃប្រតិបត្តិការ និងស្ថានភាពទីផ្សារនៅពេលនោះ។

១០.២ លោកអ្នកយល់ព្រមថា អត្រាប្តូរប្រាក់ផ្តល់ជូនដោយក្រុមហ៊ុនអាចខុសពីសូចនាករ អត្រាប្តូរប្រាក់ដែលតាំងបង្ហាញ (Displayed) ឬយោងតាមអត្រាប្តូរប្រាក់នៅលើទីផ្សារ ហើយនឹងត្រូវបញ្ចប់ និងជាប់កាតព្វកិច្ចសម្រាប់ប្រតិបត្តិការពាក់ព័ន្ធ លើកលែងតែមានការទាមទារដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការខូចខាត ឬការបាត់បង់ណាមួយដែលកើតឡើងដោយសារការប្រែប្រួលរូបិយប័ណ្ណ ឬភាពខុសគ្នារវាងអត្រាប្តូរប្រាក់គោល (Indicative Exchange Rates) និងអត្រាប្តូរប្រាក់ (Exchange Rate) ដែលបានក្រុមហ៊ុនផ្តល់ជូនក្នុងពេលដំណើរការប្រតិបត្តិការ។

ប្រការ ១១៖ ពន្ធ

១១.១ លោកអ្នកត្រូវអនុវត្តកាតព្វកិច្ចបង់ពន្ធ ឬថ្លៃសេវាសាធារណៈផ្សេងៗរបស់លោកអ្នក ដែលទាក់ទងនឹងការប្រើប្រាស់ ផលិតផល ឬសេវាកម្ម របស់ក្រុមហ៊ុនពាក់ព័ន្ធណាមួយ ដែលអាចជា គណនី ប្រតិបត្តិការ សេវាកម្ម ផលិតផល ឬ ទ្រព្យសម្បត្តិផ្សេងទៀត។ ប្រសិនបើតម្រូវដោយច្បាប់ ឬ គោលការណ៍របស់ក្រុមហ៊ុនក្នុងការកាត់ទុក ប្រមូល ឬ បង់ពន្ធណាមួយ នោះលោកអ្នកអនុញ្ញាតឲ្យក្រុមហ៊ុនធ្វើដូច្នោះ ព្រមទាំង ឬ ប្រមូលចំនួនទឹកប្រាក់ដែលពាក់ព័ន្ធនោះ ស្រមតាមច្បាប់ជាធរមាន។

១១.២ សម្រាប់ការទូទាត់ណាមួយដែលលោកអ្នកត្រូវបង់ឲ្យក្រុមហ៊ុន លោកអ្នកធានាថា ក្រុមហ៊ុននឹងទទួលបានប្រាក់ទូទាត់ពេញលេញដោយគ្មានការកាត់ពន្ធ លើកលែងតែមានការទាមទារដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន ឬមានការចែងផ្សេងពីនេះនៅក្នុងឧបសម្ព័ន្ធជាក់លាក់ណាមួយ។ ពន្ធណាមួយដែលត្រូវបានដាក់លើការទូទាត់ អត្ថប្រយោជន៍ ឬចំនួនទឹកប្រាក់ដែលត្រូវបង់ឲ្យ **លោកអ្នក** គឺនឹងត្រូវទទួលខុសត្រូវដោយ **លោកអ្នក** ផ្ទាល់ ហើយក្រុមហ៊ុនមិនមានកាតព្វកិច្ចក្នុងការបន្ថែមប្រាក់ (gross up) សងវិញ ឬផ្តល់សំណងណាមួយចំពោះពន្ធទាំងនោះឡើយ។

ប្រការ ១២៖ ការទទួលខុសត្រូវរបស់លោកអ្នក

១២.១ លោកអ្នកយល់ព្រមអនុវត្តវិធានការសមស្រប ដើម្បីការពារគណនី និងឧបករណ៍របស់លោកអ្នក ពីការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត។ ក្នុងករណីមានប្រតិបត្តិការដែលគ្មានការអនុញ្ញាត លោកអ្នកត្រូវទទួលខុសត្រូវ ប្រសិនបើឧប្បត្តិហេតុនោះកើតឡើងដោយសារការធ្វេសប្រហែស ឬការមិនអនុវត្តតាមវិធានសុវត្ថិភាពនានា។

១២.២ លោកអ្នកត្រូវទទួលខុសត្រូវចំពោះការខូចខាត ឬការខាតបង់ដែលកើតចេញពីសេចក្តីណែនាំរបស់អតិថិជន ការធ្វេសប្រហែស ការគៃបន្លំ ឬការបំពានលើកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ ពាក់ព័ន្ធនឹងការប្រើប្រាស់ផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុន។

១២.៣ លោកអ្នកយល់ព្រមផ្តល់សំណង និងការពារក្រុមហ៊ុនឲ្យរួចផុតពីការទាមទារ ឬការខូចខាត ដោយសាគីណាមួយ ដែលកើតចេញពី ឬពាក់ព័ន្ធនឹងការប្រើប្រាស់ផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនដោយលោកអ្នក។ លោកអ្នកត្រូវសងសំណងជាប្រាក់ជាបន្ទាន់ដល់ក្រុមហ៊ុន ប្រសិនបើក្រុមហ៊ុនត្រូវទទួលខុសត្រូវដោយសារតែសេចក្តីណែនាំរបស់អតិថិជន ការធ្វេសប្រហែស ការគៃបន្លំ ឬការរំលោភបំពានលើកាតព្វកិច្ច ឬការប្រើប្រាស់ផលិតផល ឬសេវាកម្មក្រុមហ៊ុនរបស់លោកអ្នក។

ប្រការ ១៣៖ ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវរបស់ក្រុមហ៊ុន

១៣.១ ក្រុមហ៊ុននីមួយៗ ត្រូវទទួលខុសត្រូវទាំងស្រុងលើផលិតផល និងសេវាកម្មរបស់ខ្លួន។ ការទទួលខុសត្រូវដែលកើតចេញពី ឬពាក់ព័ន្ធនឹងផលិតផល ឬសេវាកម្មជាក់លាក់ណាមួយនឹងជាទំនួលខុសត្រូវរបស់ក្រុមហ៊ុនដែលផ្តល់ផលិតផល ឬសេវាកម្មនោះតែមួយគត់។

១៣.២ មិនមានក្រុមហ៊ុនណាមួយក្រោម កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ នឹងទទួលខុសត្រូវលើសកម្មភាព ការមិនអនុវត្ត ការខកខាន ឬការបាត់បង់ណាមួយ ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងផលិតផល សេវាកម្ម ឬប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សេងទៀតឡើ

យ។ លោកអ្នកយល់ព្រមថា មិនមានការទាមទាណាមួយទៅលើក្រុមហ៊ុន ចំពោះរាល់បញ្ហាដែលពាក់ព័ន្ធនឹងផលិតផល ឬសេវាកម្ម របស់ក្រុមហ៊ុនផ្សេងទៀតបានទេ។

១៣.៣ រៀរលែងតែបណ្តាលមកពីការធ្វេសប្រហែស ឬការប្រព្រឹត្តកំហុសឆ្គងដោយចេតនារបស់ក្រុមហ៊ុន ឬបុគ្គលិកដែលទទួលបានការអនុញ្ញាត ក្រុមហ៊ុន អភិបាល បុគ្គលិក និងក្រុមហ៊ុនបុត្រសម្ព័ន្ធនឹងមិនទទួលខុសត្រូវចំពោះការខូចខាត ឬការបាត់បង់ ដែលលោកអ្នក ឬបុគ្គលណាមួយទទួលរង ដោយសារតែ៖

(១) ការដក ការផ្អាក ឬការលុបចោលប្រតិបត្តិការ ដែលលោកអ្នកបានចាប់ផ្តើម ឬការបរាជ័យក្នុងការអនុវត្ត ឬអនុវត្តតាមការបញ្ជា ឬសេចក្តីណែនាំរបស់អតិថិជន មិនថាការបរាជ័យនោះបណ្តាលមកពីស្ថានភាព ឬព្រឹត្តិការណ៍ណាមួយ ដែលនៅក្រៅការគ្រប់គ្រងរបស់ក្រុមហ៊ុននោះទេ។

(២) ការបរាជ័យ ឬការខូចខាតផ្នែកមេកានិច អេឡិចត្រូនិក ឬប្រព័ន្ធផ្សព្វផ្សាយទូរគមនាគមន៍ និងប្រព័ន្ធកុំព្យូទ័ររបស់ក្រុមហ៊ុន ឬឧបករណ៍ផ្សេងៗទៀត ឬការដំឡើង និងប្រតិបត្តិការរបស់វា។

(៣) ការបញ្ជូនមិនពេញលេញ ឬមានកំហុសនៃការបញ្ជា ឬសេចក្តីណែនាំរបស់អតិថិជន ឬកំហុសក្នុងការអនុវត្តការបញ្ជា ឬសេចក្តីណែនាំរបស់អតិថិជន រួមទាំងការពន្យារពេល ការបាត់បង់ ការចំណាយ ឬការខូចខាតណាមួយចំពោះលោកអ្នក ឬរងផលប៉ះពាល់ដោយសារតែបញ្ហានោះ។

(៤) ការពន្យារពេល ការរាំងស្ទះ ឬការផ្អាកដែលបណ្តាលមកពីតតិយជន មិនថាជាអ្នកផ្តល់សេវាកម្ម ឬអ្នកផ្តត់ផ្គង់ឧបករណ៍ដែលបង្កឲ្យមានការរំខាន ឬប៉ះពាល់ដល់សកម្មភាពរបស់ក្រុមហ៊ុន។

(៥) ការរំខានសេវាកម្មដោយសារករណីប្រជាសក្តិ ការបញ្ជាទិញ ឬសេចក្តីណែនាំរបស់អតិថិជនដែលមិនពេញលេញ ឬមានកំហុស ឬកំហុសក្នុងការអនុវត្តការបញ្ជា ឬសេចក្តីណែនាំរបស់អតិថិជន ដែលបណ្តាលមកពីអតិថិជនផ្ទាល់។

១៣.៤ ការពន្យារពេលក្នុងការអនុវត្ត ឬការមិនអនុវត្តសិទ្ធិណាមួយដោយក្រុមហ៊ុន តាមច្បាប់ បទប្បញ្ញត្តិ គោលនយោបាយផ្ទៃក្នុង នីតិវិធី សេចក្តីណែនាំ និងខចែង និងលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ មិនត្រូវបានចាត់ទុកថាជាការបោះបង់សិទ្ធិរបស់ក្រុមហ៊ុន ឬការយល់ព្រមឲ្យមានការបំពានលើកិច្ចព្រមព្រៀងដោយលោកអ្នកនោះទេ។

ប្រការ ១៤៖ ការដោះស្រាយបណ្តឹង

១៤.១ រាល់បណ្តឹង វិវាទ ឬការសាកសួរណាមួយ ដែលកើតចេញពីផលិតផល ឬសេវាកម្ម ត្រូវបានដោះស្រាយដោយផ្តាច់មុខដោយក្រុមហ៊ុនដែលផ្តល់ផលិតផល ឬសេវាកម្មនោះ។ លោកអ្នកយល់ព្រម ដាក់បញ្ជូនវិវាទទាំងអស់ទៅកាន់ក្រុមហ៊ុនដែលពាក់ព័ន្ធ ដោយផ្ទាល់ តាមរយៈបណ្តាញ (Channels) របស់ក្រុមហ៊ុនបានកំណត់ និងអនុលោមតាមនីតិវិធីដោះស្រាយវិវាទផ្ទៃក្នុង និងកាតព្វកិច្ចអនុលោមភាពរបស់ក្រុមហ៊ុននោះ។

១៤.២ ក្រុមហ៊ុននីមួយៗត្រួតពិនិត្យ និងដោះស្រាយវិវាទដោយអនុលោមតាមគោលការណ៍របស់ខ្លួន កាលកំណត់ និង/ឬបទប្បញ្ញត្តិដែលតម្រូវដោយច្បាប់។ លោកអ្នកត្រូវផ្តល់រាល់ព័ត៌មានដែលមានភាពសមហេតុផលសម្រាប់ធ្វើការវាយតម្លៃ។

១៤.៣ ប្រសិនបើវិវាទមិនអាចដោះស្រាយតាមរយៈដំណើរការដោះស្រាយវិវាទផ្ទៃក្នុងរបស់ក្រុមហ៊ុននីមួយៗបានទេ វិវាទនោះត្រូវតែត្រូវបានបញ្ជូនបន្ត ឬបញ្ចប់តាមច្បាប់ និងយន្តការដោះស្រាយវិវាទដែលបានកំណត់ក្នុង កិច្ចព្រមព្រៀងអតិថិជននៃផលិតផលជាក់លាក់នេះ។

១៤.៤ វិវាទណាមួយដែលទាក់ទងនឹងផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនមួយ នឹងមិនបង្កើតឱ្យការទាមទា ទំនួលខុសត្រូវ ឬការកិច្ចក្នុងការដោះស្រាយវិវាទលើក្រុមហ៊ុនផ្សេងទៀតនៅក្រោម កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះឡើយ។

១៤.៥ លោកអ្នករក្សាសិទ្ធិ ក្នុងការបញ្ជូនវិាទដែលមិនទាន់ដោះស្រាយ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដែលគ្រប់គ្រងក្រុមហ៊ុនពាក់ព័ន្ធ ក្នុងករណីដែលច្បាប់អនុញ្ញាត។

ប្រការ ១៥៖ ព័ត៌មានសម្ងាត់

១៥.១ ការរក្សាទុកព័ត៌មានរបស់លោកអ្នកឲ្យមានឯកជនភាព និងការណ៍សម្ងាត់ គឺជាគោលការណ៍សំខាន់មួយរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនប្តេជ្ញាចិត្តខិតខំប្រឹងប្រែង និងធ្វើឲ្យអស់ពីសមត្ថភាពដើម្បីធានាថាទិន្នន័យឯកជន និងហិរញ្ញវត្ថុរបស់លោកអ្នកត្រូវបានការពារ។ លោកអ្នកអាចរកគោលការណ៍ឯកជនភាពពេញលេញដែលបានភ្ជាប់មកជាមួយកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។

១៥.២ ស្របតាមវិសាលភាពដែលច្បាប់អនុញ្ញាត លោកអ្នកយល់ដឹងយ៉ាងពេញលេញថា ឯកជនភាព និងការណ៍សម្ងាត់របស់លោកអ្នកអាចមិនត្រូវបានរក្សាទុកគ្រប់ពេលវេលានោះទេ។ បន្ទាប់ពីក្រុមហ៊ុនបានខិតខំអស់ពីវិធានសុវត្ថិភាពទាំងអស់ដោយប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងហើយ លោកអ្នកយល់ព្រមថា ក្រុមហ៊ុនមិនត្រូវទទួលខុសត្រូវចំពោះសុវត្ថិភាពនៃព័ត៌មានណាមួយ ដែលលោកអ្នកបានបញ្ចូលទៅក្នុងប្រព័ន្ធក្រុមហ៊ុនតាមរយៈមធ្យោបាយណាមួយរបស់លោកអ្នក ដូចជាសេវាធនាគារចល័ត (mobile banking) ឬអ៊ីនធឺណិត ដែលមិនមែនជាកំហុសរបស់ក្រុមហ៊ុននោះទេ។ ដូច្នេះ លោកអ្នកទទួលស្គាល់ និងយល់ព្រមទទួលយកហានិភ័យ នៃការចូលប្រើដោយគ្មានការអនុញ្ញាតពីតតិយជន ទៅលើព័ត៌មានដែលមានក្នុងប្រព័ន្ធក្រុមហ៊ុន។ លោកអ្នកព្រមព្រៀងមិនឲ្យក្រុមហ៊ុនទទួលខុសត្រូវ ចំពោះការចូលទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬការបាត់បង់ ឬការខូចខាតណាមួយដែលបណ្តាលមកពីបញ្ហានេះឡើយ។

ប្រការ ១៦៖ ការបញ្ចប់កិច្ចព្រមព្រៀង

១៦.១ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ មានអានុភាពចាប់ពីកាលបរិច្ឆេទទទួលយក និងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទដាក់ឲ្យដំណើរការផលិតផល និងសេវាកម្មនីមួយៗ ហើយនឹងបន្តរហូតដល់ភាគីណាមួយបញ្ចប់ទំនាក់ទំនងជាមួយភាគីមួយទៀត។

១៦.២ លោកអ្នកអាចបញ្ចប់ទំនាក់ទំនងរបស់លោកអ្នក ជាមួយក្រុមហ៊ុនណាមួយ ក្រោមកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននៃក្រុមហ៊ុនរ៉ូយាល់គ្រុបនេះ ដោយដាក់សំណើសុំបញ្ចប់ដោយផ្ទាល់ទៅកាន់ក្រុមហ៊ុននោះ តាមរយៈបណ្តាញ (Channels) ដែលបានកំណត់។ ក្រុមហ៊ុននីមួយៗនឹងដំណើរការ ការបញ្ចប់តាមនីតិវិធីផ្ទៃក្នុង កាតព្វកិច្ចអនុលោមភាព និងកិច្ចព្រមព្រៀងអតិថិជននៃផលិតផលដាក់លាក់។

១៦.៣ ការបញ្ចប់ទំនាក់ទំនងរបស់លោកអ្នកជាមួយក្រុមហ៊ុនមួយណាមួយ នឹងអនុវត្តតែចំពោះផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុននោះប៉ុណ្ណោះ ហើយនឹងមិនប៉ះពាល់ដល់ទំនាក់ទំនងរបស់លោកអ្នកជាមួយក្រុមហ៊ុនផ្សេងទៀត ឬផលិតផល និងសេវាកម្មក្រោមកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ ឡើយ។

១៦.៤ មុនពេលការបញ្ចប់មានប្រសិទ្ធិភាព លោកអ្នកត្រូវតែទូទាត់កាតព្វកិច្ច ដែលនៅសេសសល់ទាំងអស់ រួមបញ្ចូលតែមិនកម្រិតត្រឹមប្រតិបត្តិការ ថ្លៃសេវា ថ្លៃឈ្នួល និងតម្រូវការអនុលោមភាពដែលពាក់ព័ន្ធនឹងផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុន ដែលបានបញ្ចប់ទំនាក់ទំនង។

១៦.៥ ក្រុមហ៊ុននីមួយៗរក្សាសិទ្ធិ ក្នុងការផ្អាក ឬបញ្ចប់ទំនាក់ទំនងរបស់ខ្លួនជាមួយលោកអ្នក ដោយអនុវត្តតាមគោលការណ៍របស់ក្រុមហ៊ុន ច្បាប់ដែលអនុវត្តបាន និងលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងអតិថិជនរបស់ក្រុមហ៊ុននីមួយៗ។

១៦.៦ ការបញ្ចប់ទៅលើផលិតផល ឬសេវាកម្មណាមួយ ឬការបញ្ចប់ទំនាក់ទំនងរបស់លោកអ្នកជាមួយក្រុមហ៊ុនណាមួយ មិនត្រូវបានចាត់ទុកថាបានបញ្ចប់កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះឡើយ លុះត្រាតែលោកអ្នកបានបញ្ចប់ទំនាក់ទំនងទាំងស្រុងជាមួយក្រុមហ៊ុនទាំងអស់ដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ។

ប្រការ ១៧៖ អនុប្បទាន

១៧.១ លោកអ្នកមិនមានសិទ្ធិក្នុងការផ្ទេរ ទាំងស្រុង ឬផ្នែកណាមួយ នៃសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះទៅឲ្យតតិយជន ដោយមិនមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនឡើយ។ លោកអ្នកយល់ព្រមថា ក្រុមហ៊ុនអាចផ្ទេរ ឬផ្តល់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន ទៅឲ្យអនុប្បទាយី ឬអ្នកទទួលបន្តបាន ហើយលោកអ្នកយល់ព្រមថា៖

(១) លោកអ្នកត្រូវចុះហត្ថលេខាលើឯកសារដែលចាំបាច់ ដើម្បីអនុញ្ញាតឲ្យមានការផ្ទេរ ឬការបញ្ជូន និងដើម្បីអនុញ្ញាតឲ្យអនុប្បទាយី ឬអ្នកទទួលបន្តក្លាយជាភាគី។

(២) ក្នុងករណីមានអនុប្បទាន ឬការផ្តល់សិទ្ធិ ឬកាតព្វកិច្ចទៅឲ្យបុគ្គលណាមួយដោយក្រុមហ៊ុន លោកអ្នកត្រូវធ្វើការជាមួយអនុប្បទាយី ឬអ្នកទទួលបន្ត សម្រាប់បញ្ហានោះ។

ប្រការ ១៨៖ វិសោធកម្ម

១៨.១ លើកលែងតែមានការបញ្ជាក់ជាក់លាក់ក្នុងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ លោកអ្នកយល់ដឹង និងព្រមព្រៀងថា ក្រុមហ៊ុនអាចកែប្រែ ផ្លាស់ប្តូរ កែសម្រួល បន្ថែម ឬដកចេញផ្នែកណាមួយជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ ដោយជូនដំណឹងដល់លោកអ្នក។ ការកែប្រែណាមួយនឹងត្រូវមានប្រសិទ្ធភាព លុះត្រាតែក្រុមហ៊ុនបានផ្សព្វផ្សាយលើគេហទំព័រ និងបណ្តាញក្រុមហ៊ុនផ្សេងទៀត ដែលក្រុមហ៊ុនយល់ថាសមស្រប ឬនៅកាលបរិច្ឆេទប្រសិទ្ធិភាពដែលក្រុមហ៊ុនអាចបញ្ជាក់បាន។

១៨.២ ដោយបន្តប្រើប្រាស់ផលិតផល និងសេវាកម្មរបស់យើងបន្ទាប់ពីការកែប្រែមានប្រសិទ្ធភាព លោកអ្នកត្រូវបានចាត់ទុកថាបានយល់ព្រមនឹងការកែប្រែនោះ។ ក្នុងករណីដែលការកែប្រែមានផលប៉ះពាល់ដល់ប្រភេទ បរិមាណ តម្លៃ ថ្លៃសេវា ឬគុណភាពនៃផលិតផល និង/ឬសេវាកម្ម ឬក្នុងករណីដែលតម្រូវដោយច្បាប់ជាធរមាន ក្រុមហ៊ុននឹងផ្តល់ការជូនដំណឹងជាមុន និងដោយទទួលបានការយល់ព្រមពីលោកអ្នក។ ការយល់ព្រមបែបនេះអាចទទួលបានតាមរយៈការទទួលយកតាមបណ្តាញណាមួយរបស់ក្រុមហ៊ុន។ ប្រសិនបើលោកអ្នកមិនយល់ព្រមទេ លោកអ្នកអាចបញ្ឈប់ផលិតផល ឬសេវាកម្មពាក់ព័ន្ធ និងស្នើសុំបិទគណនី ឬទំនាក់ទំនងពាក់ព័ន្ធស្របតាមកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។

ប្រការ ១៩៖ ការជូនដំណឹង

១៩.១ ការជូនដំណឹង ឬទំនាក់ទំនងណាមួយនឹងត្រូវមានអានុភាព ចាប់ពីពេលដែលត្រូវបានទទួល ឬត្រូវបានចាត់ទុកថាត្រូវបានទទួលលើកលែងតែមានការបញ្ជាក់អំពីពេលវេលា។

១៩.២ ការជូនដំណឹង ឬទំនាក់ទំនងណាមួយត្រូវបានចាត់ទុកថាត្រូវបានទទួល ក្នុងករណីដូចខាងក្រោម៖

(១) ប្រសិនបើបានផ្សព្វផ្សាយលើគេហទំព័ររបស់ក្រុមហ៊ុន ឬផ្តល់តាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងទៀតដែលក្រុមហ៊ុនឃើញថា សមស្រប។

(២) ប្រសិនបើជាលាយលក្ខណ៍អក្សរ និងបញ្ជូនដោយផ្ទាល់ដៃ ឬតាមសេវាដឹកជញ្ជូន នៅកាលបរិច្ឆេទដែលត្រូវបានជញ្ជូន។

(៣) ប្រសិនបើផ្ញើតាមប្រៃសណីយ៍ ០៣ (បី) ថ្ងៃធ្វើការបន្ទាប់ពីការផ្ញើ (ឬ ០៧ (ប្រាំពីរ) ថ្ងៃធ្វើការបើផ្ញើពីប្រទេសមួយទៅប្រទេសមួយទៀត)។

(៤) ប្រសិនបើផ្ញើតាមសារអេឡិចត្រូនិក SMS ការជូនដំណឹងនៅក្នុងកម្មវិធី ឬបណ្តាញទំនាក់ទំនងអេឡិចត្រូនិកស្រដៀងគ្នា នៅពេលដែលសារបែបនេះត្រូវបានផ្តល់ជូនអ្នកទទួល។

(៥) ប្រសិនបើផ្ញើតាមតេឡេក្រាម (Telegram) នៅពេលសារនោះត្រូវបានមើលឃើញថាត្រូវបានអានដោយអ្នកទទួល។

(៦) ប្រសិនបើផ្ញើតាមអ៊ីម៉ែល (ក) នៅពេលអ្នកផ្ញើទទួលបានសារឆ្លើយតបស្វ័យប្រវត្តិបញ្ជាក់អំពីការបញ្ជូន (រួមទាំងសារចេញក្រៅការិយាល័យ ឬសារប្រហាក់ប្រហែល ឬ (ខ) បួនម៉ោងបន្ទាប់ពីពេលដែលអ៊ីម៉ែលត្រូវបានផ្ញើ (យោងតាមឧបករណ៍ដែលបានផ្ញើអ៊ីម៉ែលចេញ) លើកលែងតែអ្នកផ្ញើទទួលបានសារស្វ័យប្រវត្តិថាអ៊ីម៉ែលមិនត្រូវបានបញ្ជូន ដែលករណីណាមួយខាងលើកើតឡើងជាមុននឹងត្រូវយកមកអនុវត្ត។

ប្រការ ២០៖ ការទំនាក់ទំនង និងសេវាកម្មអតិថិជន

២០.១ ក្រុមហ៊ុននីមួយៗក្សាទុកបណ្តាញ (channels) សេវាកម្មអតិថិជនដាច់ដោយឡែក។ លោកអ្នកត្រូវតែទាក់ទងទៅកាន់ក្រុមហ៊ុនដែលទទួលបន្ទុកសម្រាប់ ការសាកសួរអំពីសេវាកម្ម បញ្ហាប្រតិបត្តិការ សំណួរទាក់ទងនឹងផលិតផល ឯកសារពាក្យបណ្តឹង ឬវិវាទការផ្លាស់ប្តូរ ឬបញ្ចប់គណនី និងបញ្ហាដែលមានលក្ខណៈស្រដៀងគ្នានេះ។

២០.២ ព័ត៌មានទំនាក់ទំនងនៃក្រុមហ៊ុននីមួយៗ

- **ធនាគារវីង (ខេមបូឌា) ម.ក**

  អាសយដ្ឋាន៖ អគារវីងថៅវើ មហាវិថីព្រះមុនីវង្ស កែងមហាវិថីកម្ពុជាក្រោម ភូមិ៦ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ

  អ៊ីម៉ែល៖ care.centre@wingbank.com.kh

  ទូរសព្ទ៖ +៨៥៥ ២៣ ៩៩៩ ៩៨៩

- **Royal Group Funds Co., Ltd.**

  អាសយដ្ឋាន៖ ……

  អ៊ីម៉ែល៖ ……

  ទូរសព្ទ៖ ……

- **Royal Group Exchange Co., Ltd.**

  អាសយដ្ឋាន៖ ……

  អ៊ីម៉ែល៖ ……

  ទូរសព្ទ៖ ……

- **ក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក**

  អាសយដ្ឋាន៖ អគារលេខ ២៤៦ មហាវិថីព្រះមុនីវង្ស (ផ្លូវ ៩៣) ភូមិ ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

  អ៊ីម៉ែល៖ all@royalgroupsecurities.com.kh

  ទូរសព្ទ៖ +៨៥៥ ២៣ ៩៩៤ ៩៩៩

ប្រការ ២១៖ ច្បាប់គ្រប់គ្រង និងដោះស្រាយវិវាទ

២១.១ រាល់វិវាទ ភាពមិនសមស្រប ឬការទាមទារណាមួយដែលកើតឡើង ឬទាក់ទងនឹងកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ រួមទាំងបញ្ហាពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត និងការបញ្ចប់ ត្រូវដោះស្រាយដោយសន្តិវិធី និងក្រៅប្រព័ន្ធតុលាការ ដោយអនុលោមតាមគោលការណ៍ដោះស្រាយពាក្យបណ្តឹងដែលអាចអនុវត្តបានរបស់ក្រុមហ៊ុនពាក់ព័ន្ធ។

២១.២ ប្រសិនបើវិវាទមិនអាចឈានទៅដល់ដំណោះស្រាយក្នុងរយៈពេល ៦០ (ហុកសិប) (ឬរយៈពេលផ្សេងទៀតដែលបានបញ្ជាក់ដោយក្រុមហ៊ុនពាក់ព័ន្ធ) វិវាទនោះនឹងត្រូវបញ្ជូនទៅដោះស្រាយស្របតាមយន្តការដោះស្រាយវិវាទដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធដែលអាចអនុវត្តបាននៃកិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះ។ ក្នុងករណីដែលគ្មានយន្តការដោះស្រាយវិវាទណាមួយដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធដែលពាកព័ន្ធនោះទេ វិវាទដែលមិនទាន់ដោះស្រាយនឹងត្រូវបញ្ជូនទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២២៖ ភាសា

កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជននេះត្រូវបានធ្វើឡើងជាភាសាខ្មែរ ហើយអាចត្រូវបានបកប្រែទៅជាភាសាផ្សេងទៀតជាភាសាបន្ថែមសម្រាប់ភាពងាយស្រួលក្នុងការប្រើប្រាស់។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងនេះ ភាសាខ្មែរត្រូវមានអាទិភាព។

ឧបសម្ព័ន្ធ ឃ៖ កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន
នៃក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក

កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរមូលបត្រនៅលើផ្សារ CSX

ប្រការ ១៖ សាវតា

១.១ ក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក ជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណឲ្យធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាក្រុមហ៊ុនធានាទិញមូលបត្រ ដោយនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**)។

១.២ លោកអ្នក មានបំណងជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាជួញដូរ និង ផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

១.៣ អនុលោមតាមមាត្រា៥៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រការ៦ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអតិថិជន។

១.៤ ភាគីទាំងពីរត្រូវអនុវត្តតាមលក្ខណ្ឌនៃកិច្ចព្រមព្រៀងនេះដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

ប្រការ ២៖ និយមន័យ

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវឲ្យនិយមន័យដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងបទប្បញ្ញត្តិ ដែលកំណត់ដោយ ន.ម.ក. និងច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។ និយមន័យបន្ថែមខាងក្រោមនឹងត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ៖

២.១ **សាច់ប្រាក់អតិថិជនអាចប្រើប្រាស់បាន៖** សំដៅដល់ប្រាក់ដែលអាចប្រើប្រាស់បាននៅក្នុងគណនីសាច់ប្រាក់អតិថិជនក្នុងពេលជាក់លាក់មួយ សម្រាប់ការបញ្ជាទិញមូលបត្ររបស់អតិថិជនដែលយកសមតុល្យក្នុងគណនីសាច់ប្រាក់អតិថិជន ដកចេញនូវរាល់បំណុលអតិថិជនទាំងអស់ ការបញ្ជាទិញពីមុនទាំងអស់របស់អតិថិជន ព្រមទាំងប្រាក់ដែលអតិថិជនបានស្នើដក ឬ ស្នើទូទាត់ទៅតតិយជន។

២.២ **គណនីសាច់ប្រាក់អតិថិជន** (Client Money Account)**:** សំដៅដល់ គណនីធនាគារដែលបានកំណត់ជាក់លាក់ និងគ្រប់គ្រងដោយក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក. ដោយប្រើប្រាស់តែសម្រាប់ការកាន់កាប់ប្រាក់ដែលជាកម្មសិទ្ធិរបស់អតិថិជន ប៉ុណ្ណោះ ពាក់ព័ន្ធនឹងសកម្មភាពមូលបត្រ រួមទាំង ប្រាក់បញ្ញើ ការទូទាត់ប្រតិបត្តិការមូលបត្រ និងការដកប្រាក់ចេញពីគណនីជួញដូររបស់អតិថិជន។

២.៣ **ពាក្យស្នើសុំបើកគណនីអតិថិជន** (Customer Account Opening Form)**:** សំដៅដល់ ទម្រង់ស្នើសុំបើកគណនី រួមជាមួយឯកសារគាំទ្រ និងព័ត៌មានទាំងអស់ ដែលបានបំពេញ និងផ្តល់ដោយ អតិថិជន ជូន ក្រុមហ៊ុន សម្រាប់គោលបំណងបើក និងរក្សាទុកគណនីរបស់អតិថិជនជាមួយក្រុមហ៊ុន និងការចូលប្រើប្រាស់ សេវាកម្ម ដែលអាចត្រូវបានកែប្រែ ឬធ្វើបច្ចុប្បន្នភាពពីពេលមួយទៅពេលមួយ។

២.៤ **ប្រតិបត្តិការរក្សាទុកមូលបត្រ**(Securities Depository)**:** សំដៅដល់ ស្ថាប័ន និង/ឬ ប្រព័ន្ធកត់ត្រាតាមសៀវភៅ (book-entry system) ដែលមានទំនួលខុសត្រូវក្នុងការរក្សាសុវត្ថិភាពមូលបត្រ ការថែរក្សាកំណត់ត្រាកម្មសិទ្ធិ និងការសម្របសម្រួលការផ្ទេរ និងការទូទាត់ប្រតិបត្តិការមូលបត្រ ស្របតាមប្រតិបត្តិការទីផ្សារ។

២.៥ **ប្រព័ន្ធជួញដូរចល័ត** (Mobile Trading System)**:** សំដៅដល់ វេទិកាជួញដូរអេឡិចត្រូនិក ដែលត្រូវបានផ្តល់ជូនតាមរយៈកម្មវិធីលើទូរស័ព្ទចល័ត ដូចជា កម្មវិធី CSX Trade App ដែលអនុញ្ញាតឱ្យអតិថិជនចូលប្រើគណនីជួញដូរមូលបត្ររបស់ខ្លួន ដោយប្រើស្មាតហ្វូន ឬឧបករណ៍ចល័តផ្សេងទៀត។ តាមរយៈប្រព័ន្ធនេះ ជាទូទៅ អតិថិជនអាចមើលព័ត៌មានទីផ្សារ តាមដានផលប័ត្ររបស់ខ្លួន ដាក់បញ្ជាទិញ ឬលក់ ពិនិត្យស្ថានភាពបញ្ជា និងតាមដានសកម្មភាពជួញដូរពីចម្ងាយ ដោយអាស្រ័យលើមុខងារ និងវិធានត្រួតពិនិត្យ ដែលបានផ្តល់ដោយក្រុមហ៊ុនមូលបត្រ និងប្រព័ន្ធទីផ្សាររបស់ CSX។

២.៦ **ធនាគារ៖** សំដៅធនាគាពាណិជ្ជដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងការគ្រប់គ្រងនៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

២.៧ **ព័ត៌មានអតិថិជន៖** សំដៅដល់ព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលផ្តល់ឲ្យក្រុមហ៊ុននៅពេលដែលបើកគណនីអតិថិជន ហើយត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។

២.៨ **បំណុលអតិថិជន៖** សំដៅដល់ប្រាក់ដែលអតិថិជនជំពាក់ក្នុងការទូទាត់ទៅបុគ្គលផ្សេងទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ឬច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាអាទិ៍ កម្រៃជើងសា ថ្លៃសេវា លាភការផ្សេងៗ ពន្ធ ឬចំណាយផ្សេងទៀតដែលទាក់ទងនឹងការលក់ ឬការទិញមូលបត្រ និងកម្រៃរដ្ឋបាលដែលទាក់ទងនឹងការធ្វើប្រតិបត្តិការលើគណនីសាច់ប្រាក់អតិថិជន។

២.៩ **បញ្ជាអតិថិជន៖** សំដៅសល់ការបញ្ជាទិញ ឬលក់មូលបត្ររបស់អតិថិជនទៅក្រុមហ៊ុន។

២.១០ **ក្រមសីលធម៌វិជ្ជាជីវៈ៖** សំដៅដល់ប្រកាសស្តីពីក្រមសិលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

២.១១ **អាជ្ញាបណ្ណ៖** សំដៅដល់អាជ្ញាបណ្ណដែលផ្តល់អោយក្រុមហ៊ុនដោយ ន.ម.ក.។

២.១២ **ការជួញដូរមូលបត្រ៖** សំដៅដល់ការជួញដូរមូលបត្រដែលបានចុះបញ្ជីនៅផ្សារមូលបត្រប្រតិស្រុត។

២.១៣ **ផ្សារមូលបត្រ (Securities Exchange):** សំដៅដល់ ទីផ្សារដែលមានការរៀបចំ និងគ្រប់គ្រងដោយបទប្បញ្ញត្តិច្បាប់ ដែលមូលបត្រ ដូចជា ភាគហ៊ុន សញ្ញាប័ណ្ណ និងឧបករណ៍ហិរញ្ញវត្ថុដែលទទួលបបានការអនុម័តផ្សេងទៀត ត្រូវបានចុះបញ្ជី ទិញ និងលក់ ស្របតាមច្បាប់ជាធរមាន វិធានជួញដូរ និងនីតិវិធីទីផ្សារ។

២.១៤ **សេវាកម្ម៖** សំដៅដល់ការផ្តល់សេវាជួញដូរ និងផ្តល់ព្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

២.១៥ **ប្រតិសិទ្ធិសកល៖** សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធ និងកាតព្វកិច្ចទូទៅពីអ្នកដទៃ។

២.១៦ **ប្រតិសិទ្ធិដោយឡែក៖** សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធមួយ ឬច្រើនជាកំណត់ផ្អែកតាមមូលហេតុនីមួយៗ។

ប្រការ ៣៖ បទប្បញ្ញត្តិប្រតិបត្តិការ

៣.១ ការជ្រើសរើសក្រុមហ៊ុន

៣.១.១ លោកអ្នកជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាកម្មដោយគោរពតាមលក្ខណៈនៃកិច្ចព្រមព្រៀងនេះ។ លោកអ្នកព្រមព្រៀងអនុវត្តកាតព្វកិច្ចនានាដែលកើតចេញពីការអនុវត្តអាណត្តិដោយក្រុមហ៊ុន ក្នុងដែនអនុញ្ញាតដែលផ្តល់ដោយអតិថិជនក្រោមកិច្ចព្រមព្រៀងនេះ។

៣.១.២ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការជួញដូរមូលបត្រក្នុងគណនីអតិថិជន ក្នុងនាមអតិថិជនដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជនតាមរយៈកិច្ចព្រមព្រៀងនេះ។

៣.១.៣ ក្រុមហ៊ុនត្រូវធានាថា ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណដែលអនុញ្ញាតអោយផ្តល់សេវាកម្មដល់អតិថិជន។ ក្រុមហ៊ុនត្រូវផ្តល់សេវាកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រដល់អតិថិជនស្របតាមលក្ខខណ្ឌអាជ្ញាបណ្ណដែលបានផ្តល់ដោយអគ្គនាយកនៃ ន. ម. ក. ។

៣.២ ការធ្វើបច្ចុប្បន្នកម្មព័ត៌មាន

៣.២.១ ក្រុមហ៊ុនត្រូវទទួលស្គាល់ និងព្រមព្រៀងថាក្រុមហ៊ុនបានបំពេញទម្រង់ពាក្យស្នើសុំបើកគណនីអតិថិជន ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធរបស់ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ។

៣.២.២ លោកអ្នកត្រូវធានាថា ព័ត៌មានដែលផ្តល់ឲ្យនៅពេលចុះកិច្ចព្រមព្រៀងនេះជាព័ត៌មានពិតប្រាកដ និងត្រឹមត្រូវ។

៣.២.៣ លោកអ្នកត្រូវទទួលស្គាល់ថាក្រុមហ៊ុនផ្តល់សេវាកម្មជូនអតិថិជនដោយផ្អែកលើព័ត៌មានអតិថិជន។ លោកអ្នកយល់ព្រមជូនដំណឹងភ្លាមៗទៅក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរព័ត៌មានជាសារវន្តរបស់អតិថិជន។

៣.២.៤ ក្រុមហ៊ុន ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានទាំងឡាយណាទាក់ទងនឹងក្រុមហ៊ុន នឹងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវព័ត៌មានទាំងនោះដែលកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ។ អនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈក្រុមហ៊ុនត្រូវទទួលស្គាល់ និង

យល់ព្រមថាក្រុមហ៊ុនផ្តល់ឲ្យអតិថិជន នូវព័ត៌មានជាលាយលក្ខណ៍អក្សរ មុនពេលអនុវត្តបញ្ជាក្នុងនាមអតិថិជន។ ចំណុចទី ៧ នៃកិច្ចព្រមព្រៀងនេះមិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

៣.៣ ការជួញដូរមូលបត្រ

៣.៣.១ ក្រុមហ៊ុន ត្រូវអនុវត្តការជួញដូរមូលបត្រក្នុងនាមអតិថិជននៅពេលមានបញ្ជាពីអតិថិជនតែប៉ុណ្ណោះ។ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការគណនីឆន្ទានុសិទ្ធិក្នុងនាមអតិថិជន និងមិនអនុញ្ញាតនូវរាល់បញ្ជាពីអតិថិជនឲ្យអនុវត្តការជួញដូរមូលបត្រ ដោយផ្អែកលើមូលដ្ឋានឆន្ទានុសិទ្ធិក្នុងគ្រប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការអនុញ្ញាតពី ន.ម.ក.។

៣.៣.២ អតិថិជនផ្តល់សិទ្ធិឲ្យក្រុមហ៊ុនធ្វើការងារចាំបាច់សមស្របក្នុងនាមអតិថិជន តាមបញ្ជាអតិថិជនដើម្បី៖

ក. បញ្ជូនបញ្ជារបស់អតិថិជន

ខ. ផ្ទេរមូលបត្រដែលត្រូវបានលក់ ឬទិញតាមបញ្ជារបស់អតិថិជន

គ. ជានាថារាល់ការផ្ទេរបានកត់ត្រាត្រឹមត្រូវនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

៣.៣.៣ ក្រុមហ៊ុនព្រមព្រៀងចាត់ចែងធ្វើការផ្ទេរមូលបត្រក្នុងនាមអតិថិជន ហើយត្រូវកត់ត្រាការផ្ទេរនោះ ដោយអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ និងស្របតាមវិធាន ប្រព័ន្ធ ព្រមទាំងនីតិវិធីរបស់ប្រតិបត្តិកររក្សាទុកមូលបត្រ និងបទប្បញ្ញាត្តិជាធរមាន។

៣.៣.៤ លោកអ្នកត្រូវទទួលស្គាល់និងព្រមព្រៀងថា៖

ក. ក្រុមហ៊ុនមិនត្រូវទិញមូលបត្រក្នុងនាមអតិថិជនឡើយ លើកលែងតែអតិថិជនផ្តល់ឱ្យក្រុមហ៊ុននូវប្រាក់គ្រប់គ្រាន់ក្នុងការទិញមូលបត្រ និងអតិថិជនយល់ព្រមថា មិនត្រូវធ្វើការដាក់បញ្ជាទិញមូលបត្រ នៅតម្លៃលើសពីបរិមាណប្រាក់អតិថិជនដែលមានឡើយ និង

ខ. ក្រុមហ៊ុនមិនត្រូវលក់ស៊ិតសែល (short sell) ឡើយ និងលោកអ្នកមិនត្រូវដាក់បញ្ជាលក់មូលបត្ររបស់ខ្លួនឡើយ លើកលែងតែមូលបត្រនោះបានចុះបញ្ជីនៅប្រតិបត្តិកររក្សាទុកមូលបត្រក្នុងឈ្មោះរបស់អតិថិជន និងអាចលក់បាន។

៣.៣.៥ អតិថិជនព្រមព្រៀងតាមការកំណត់នៃបញ្ជារបស់ខ្លួន ហើយត្រូវទទួលស្គាល់ និងយល់ព្រមថាបញ្ជារបស់អតិថិជននិងមិនត្រូវបានលុបចោល ឬផ្លាស់ប្តូរបន្ទាប់ពីបានអនុវត្តឡើយ។ បញ្ជារបស់អតិថិជនមិនអាចត្រូវបានលុបចោល ឬផ្លាស់ប្តូរ មុនពេលអនុវត្តតាមបញ្ជារបស់អតិថិជន លើកលែងតែអតិថិជនបានជូនដំណឹងដល់ក្រុមហ៊ុននូវការលុបចោលឬការផ្លាស់ប្តូរនោះស្របតាមការតម្រូវរបស់ក្រុមហ៊ុន។ ចំណុចទី ៨ នៃកិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

៣.៤ វិធីសាស្ត្រក្នុងការដាក់បញ្ជា

៣.៤.១ លោកអ្នកអាចដាក់បញ្ជាដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម៖

ក. ជាលាយលក្ខណ៍អក្សរ ឬ អ៊ីម៉ែល

ខ. ប្រព័ន្ធជួញដូរចល័ត (CSX Trade)

គ. តាមរយៈទូរស័ព្ទ

ឃ. តាមវិធីទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀតដែលកំណត់ដោយ ន.ម.ក.។

៣.៤.២ បញ្ជារបស់លោកអ្នកត្រូវបង្ហាញព័ត៌មានទាក់ទងនឹងការជួញដូរមូលបត្ររួមមាន ឈ្មោះមូលបត្រ ប្រភេទមូលបត្រ បរិមាណមូលបត្រ ថ្លៃមូលបត្រ និងកាលវិភ្លេទ។ ក្រុមហ៊ុនត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមអេឡិចត្រូនិចដើម្បីធ្វើជាភស្តុតាងនៃការដាក់បញ្ជា។

៣.៥ កាតព្វកិច្ចរបស់ក្រុមហ៊ុនពាក់ពាន់នឹការដាក់បញ្ជា

៣.៥.១ ក្រុមហ៊ុន ត្រូវធានាឲ្យមាននូវយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទទួលបញ្ជាពីអតិថិជនតាមរយៈទូរស័ព្ទ ឬអ៊ីម៉ែល។

៣.៥.២ ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មានដល់អតិថិជនអំពីហានិភ័យផ្សេងៗ ដែលអាចកើតមានពេលដាក់បញ្ជាតាមរយៈទូរសព្ទ អ៊ីម៉ែល និងប្រព័ន្ធជួញដូរចល័ត និង ត្រូវទទួលខុសត្រូវលើហានិភ័យនៃការអាក់រអួលប្រព័ន្ធទូរស័ព្ទ ឬអ៊ីនធើណែតផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្នុងពេលទទួលបញ្ជារបស់អតិថិជនតាមរយៈទូរស័ព្ទ ឬ អ៊ីម៉ែល។

៣.៥.៣ ក្រុមហ៊ុន ធានាកាត់បន្ថយជាអតិបរមា នូវហានិភ័យដែលកើតឡើងពាក់ព័ន្ធនឹងការបញ្ជាតាមរយៈទូរសព្ទ ឬអ៊ីម៉ែល។

៣.៥.៤ ក្រុមហ៊ុន ត្រូវជូនដំណឹងភ្លាមដល់អតិថិជនក្នុងករណីក្រុមហ៊ុនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជា។

៣.៦ កាតព្វកិច្ចរបស់លោកអ្នកពាក់ព័ន្ធនឹងការដាក់បញ្ជា

៣.៦.១ លោកអ្នក ត្រូវទទួលស្គាល់ថាបានសិក្សា និងយល់ដឹងច្បាស់លាស់អំពីហានិភ័យដែលអាចកើតមានឡើងក្នុងការដាក់បញ្ជាតាមវិធីសាស្ត្រដែលលោកអ្នកបានជ្រើសរើស។

៣.៦.២ លោកអ្នក ត្រូវទទួលស្គាល់ថាលេខទូរស័ព្ទសម្រាប់ការហៅទូរស័ព្ទ និង/ឬ អាស័យដ្ឋានអ៊ីម៉ែលសម្រាប់ដាក់បញ្ជាដែលបានផ្តល់ជូនក្រុមហ៊ុន ពិតជាត្រឹមត្រូវប្រាកដមែន ហើយអតិថិជនទទួលខុសត្រូវលើរាល់ការដាក់បញ្ជាតាមរយៈទូរស័ព្ទ អាសយដ្ឋានអ៊ីម៉ែល និងតាមប្រព័ន្ធជួញដូរចល័ត (Mobile Trading System – MTS)។)

៣.៦.៣ លោកអ្នក យល់ព្រមឲ្យក្រុមហ៊ុនថតសម្លេងទុកជាភស្តុតាងពេលអតិថិជនដាក់បញ្ជា ឬពេលក្រុមហ៊ុនជូនដំណឹងអំពីព័ត៌មាននៃការអនុវត្តបញ្ជាតាមរយៈការហៅទូរស័ព្ទ។

៣.៦.៤ លោកអ្នក ត្រូវជូនដំណឹងភ្លាមដល់ក្រុមហ៊ុនក្នុងករណីអតិថិជនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជា បានប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជា។

៣.៧ ការបដិសេធទទួលបញ្ជា

៣.៧.១ ក្រុមហ៊ុន មិនត្រូវអនុវត្តតាមបញ្ជាអតិថិជនទេ ប្រសិនបើការអនុវត្តបញ្ជាអតិថិជននោះផ្ទុយនឹងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ឬលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ ក្រុមហ៊ុនមិនទទួលខុសត្រូវលើការខាតបង់ថ្លៃដើម ឬការចំណាយរបស់អតិថិជនឡើយ ដែលបណ្តាលមកពីការបដិសេធរបស់ក្រុមហ៊ុនក្នុងការអនុវត្តតាមបញ្ជារបស់អតិថិជន។

៣.៧.២ ក្រុមហ៊ុន ត្រូវជូនដំណឹងភ្លាមៗដល់អតិថិជនជាលាយលក្ខណ៍អក្សរក្នុងករណីមានការបដិសេធដូចមានចែងក្នុងកថាខណ្ឌទីមួយ ឬមានកំហុសឆ្គងក្នុងការអនុវត្តបញ្ជារបស់អតិថិជន ឬការអនុវត្តបញ្ជាដោយអនុលោមតាមលក្ខខណ្ឌនៃបញ្ជាអតិថិជន។

៣.៨ ការជូនដំណឹងការជួញដូរមូលបត្រ

៣.៨.១ ក្រុមហ៊ុនត្រូវជូនដំណឹងដល់អតិថិជននៅរាល់ប្រតិបត្តិការមូលបត្រដែលធ្វើក្នុងនាមអតិថិជនដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ អតិថិជនយល់ព្រមពិនិត្យយ៉ាងយកចិត្តទុកដាក់នូវការជូនដំណឹងនោះ ហើយជូនដំណឹងទៅក្រុមហ៊ុនវិញភ្លាមនូវភាពខុសគ្នារវាងកំណត់ត្រារបស់អតិថិជន និងព័ត៌មានដែលបង្ហាញក្នុងសេចក្តីជូនដំណឹង។

៣.៩ គណនីសាច់ប្រាក់អតិថិជន

៣.៩.១ លោកអ្នកផ្តល់សិទ្ធិដល់ក្រុមហ៊ុនចំពោះ៖

ក. ការដាក់តម្កល់ប្រាក់ដែលទទួលបានពីអតិថិជន ឬក្នុងនាមអតិថិជនទៅក្នុងគណនីសាច់ប្រាក់អតិថិជនដែលពាក់ព័ន្ធនឹងអតិថិជន។

ខ. ការទទួលប្រាក់ពីការលក់មូលបត្រក្នុងនាមអតិថិជន តាមបញ្ជាចូលក្នុងគណនីសាច់ប្រាក់អតិថិជន។

គ. ការទូទាត់ចេញពីគណនីសាច់ប្រាក់អតិថិជនសម្រាប់ការទិញមូលបត្រក្នុងនាមអតិថិជន តាមបញ្ជារបស់អតិថិជន។

ឃ. ការទូទាត់សងបំណុលអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រពីគណនីសាច់ប្រាក់អតិថិជន។

ង. ការទូទាត់ផ្សេងៗពីគណនីសាច់ប្រាក់អតិថិជនដែលតម្រូវដោយច្បាប់និង

ច. ការដាក់ប្រាក់ចូលនឹងការដកប្រាក់ចេញពីគណនីសាច់ប្រាក់អតិថិជននៅពេលមានបញ្ជាអតិថិជន ឬការណែនាំជាលាយលក្ខណ៍អក្សរពីអតិថិជន។

ឆ. ការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់អតិថិជន ទៅគណនីសន្សំរបស់អតិថិជននៅធនាគារដូចដែលបានបំពេញនូវក្នុងពាក្យស្នើសុំបើកគណនី។

៣.៩.២ លោកអ្នកមានសិទ្ធិទទួលរាល់ចំណូលការប្រាក់ដែលកើតមានក្នុងគណនីអតិថិជន។

៣.១០ របាយការណ៍

៣.១០.១ ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរដល់អតិថិជនទាក់ទងនឹងការជួញដូរមូលបត្រដូចខាងក្រោម៖

ក. សេចក្តីជូនដំណឹងស្តីអំពីការជួញដូរមូលបត្រដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ

ខ. របាយការណ៍ប្រតិបត្តិការប្រចាំខែក្នុងគណនីអតិថិជនដោយអនុលោមតាមប្រការ ២២ នៅក្រោមសីលធម៌ប្រជាជីវៈ

គ. របាយការណ៍ពាក់ព័ន្ធនឹងប្រាក់អតិថិជនដោយអនុលោមតាមច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ

៣.១០.២ អតិថិជនព្រមព្រៀងក្នុងការពិនិត្យយ៉ាងយកចិត្តទុកដាក់លើខ្លឹមសារនៃរបាយការណ៍ដែលផ្តល់ដោយក្រុមហ៊ុន ដើម្បីធានាថាខ្លឹមសារនៃរបាយការណ៍ដែលបានផ្តល់ឲ្យមានសង្គតិភាពនឹងកំណត់ត្រាផ្ទាល់ខ្លួន និងជូនដំណឹងដល់ក្រុមហ៊ុនភ្លាមនូវរាល់ភាពខុសគ្នាណាមួយ។

៣.១០.៣ អតិថិជនដែលបានស្នើសុំចុះឈ្មោះប្រើប្រាស់ប្រព័ន្ធជួញដូរចល័តយកព្រមដោយស្ម័គ្រចិត្តថាខ្លួនមិនត្រូវការរបាយការណ៍ដូចរៀបរាប់ខាងលើឡើយ។

៣.១១ លាភការ

៣.១១.១ ភាគីទាំងពីរទទួលស្គាល់ និងព្រមព្រៀងថា ការបង់លាភការឲ្យក្រុមហ៊ុនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបានកំណត់តាមកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែក និងអាចប្រែប្រួលតាមការកំណត់របស់ន.ម.ក ។

៣.១១.២ ក្រុមហ៊ុន អាចធ្វើបច្ចុប្បន្នកម្មកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែកនោះ នៅពេលមានការផ្លាស់ប្តូរលាភការ និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវរាល់ការផ្លាស់ប្តូរនោះ។ ដើម្បីឲ្យការដំឡើងលាភការដែលត្រូវបង់ដូចមានចែកក្នុងកិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តលុះត្រាតែកិច្ចព្រមព្រៀងនេះបានធ្វើបច្ចុប្បន្នកម្ម ហើយអតិថិជនបានជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងការយល់ព្រម។

៣.១១.៣ ក្រុមហ៊ុន ត្រូវព្រមព្រៀងថានៅពេលគិតថ្លៃសេវាពីអតិថិជនលើសចំនួនដែលមានចែកក្នុងកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែក ត្រូវបង្វិលប្រាក់ដែលបង់លើសចូលក្នុងគណនីសាច់ប្រាក់អតិថិជនវិញភ្លាមៗ និងត្រូវជូនដំណឹងជាលេងលាក់អក្សរដល់អតិថិជន។

៣.១២ ផលប្រយោជន៍ និងទំនាក់ទំនង

៣.១២.១ ក្រុមហ៊ុន ត្រូវបញ្ចាក់នូវរាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ក្រុមហ៊ុន ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រក្នុងកិច្ចព្រមព្រៀងអតិថិជនជាច់ដោយឡែក) ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

៣.១៣ ការតវ៉ា

៣.១៣.១ ករណីក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ ឬភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរដោយត្រូវមានបញ្ជាក់ឈ្មោះនិងព័ត៌មានលម្អិតនៃបុគ្គលដោះស្រាយការតវ៉ារបស់ក្រុមហ៊ុន។

៣.១៣.២ ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយវិវាទរបស់អតិថិជនក្នុងអំឡុងពេល ៧ ថ្ងៃនៅថ្ងៃធ្វើការបន្ទាប់ពីបានទទួលការតវ៉ា។

៣.១៣.៣ ក្នុងករណីដែលពាក្យបណ្តឹងមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃធ្វើការ ដោយសារភាពស្មុគស្មាញ ឬស្ថានការណ៍ផ្សេងទៀត ក្រុមហ៊ុននឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ លោកអ្នក អំពីមូលហេតុនៃការពន្យារពេល ស្ថានភាពនៃពាក្យបណ្តឹង និងរយៈពេលដែលរំពឹងទុកសម្រាប់ការដោះស្រាយ។ ក្រុមហ៊ុននឹងបន្តដោះស្រាយពាក្យបណ្តឹងនោះដោយឆាប់រហ័ស និងដោយសុចរិតភាព រហូតដល់មានការដោះស្រាយចុងក្រោយ។

៣.១៤ តំណាងរបស់អតិថិជន

៣.១៤.១ លោកអ្នក អាចជ្រើសរើសបុគ្គលក្រៅពីក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រធ្វើជាតំណាង តាមរយៈលិខិតផ្ទេរសិទ្ធិ ឬការអនុញ្ញាតដោយច្បាប់ដើម្បីដាក់បញ្ជាទិញ-លក់ ឬបញ្ជាផ្សេងទៀតក្នុងនាមអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ នៅពេលចុះកិច្ចព្រមព្រៀងនេះអតិថិជនដែលមានបំណងជ្រើសរើសបុគ្គលដែលធ្វើជាអ្នកតំណាងត្រូវបញ្ជាក់ក្នុងកិច្ចព្រមព្រៀងអតិថិជនជាច់ដោយឡែក។

៣.១៤.២ មុនទទួលបញ្ជាពីអ្នកតំណាងរបស់អតិថិជន ក្រុមហ៊ុនត្រូវតម្រូវឲ្យអតិថិជនផ្តល់ឲ្យក្រុមហ៊ុននៅឯកសារដើម ឬថតចម្លង មានបញ្ជាក់ត្រឹមត្រូវនៃការអនុញ្ញាតនូវការជ្រើសរើសអ្នកដំណាង។

៣.១៤.៣ លោកអ្នក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាម ដល់ក្រុមហ៊ុនពីការដកហូតសិទ្ធិរបស់អ្នកតំណាង។ ក្រុមហ៊ុនអាចធ្វើប្រតិបត្តិការដែលទទួលបានពីអ្នកតំណាង តាមបញ្ជាទិញលក់មូលបត្រ ឬបញ្ជាផ្សេងទៀតលើកលែងតែមានការជូនដំណឹងផ្សេងទៀតពីអតិថិជន។

៣.១៥ ការរក្សាភាពសម្ងាត់

៣.១៥.១ ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងការអនុវត្តសេវាកម្មស្របតាមកិច្ចព្រមព្រៀងនេះទៅឲ្យបុគ្គលណាផ្សេងឡើយ លើកលែងតែមានករណីណាមួយដូចខាងក្រោម

ក. មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលនូវព័ត៌មានសម្ងាត់។

ខ. មានការស្នើសុំពី ន.ម.ក ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

គ. មានការតម្រូវដោយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

៣.១៦ សេចក្តីថ្លែងព័ត៌មានហានិភ័យ

៣.១៦.១ អតិថិជនត្រូវទទួលស្គាល់ថាថ្លៃមូលបត្រអាចប្រែប្រួលឡើង ឬចុះ ហើយព័ត៌មានដែលត្រូវបានផ្តល់ឲ្យអំពីចំណូលនៃការវិនិយោគ ឬថ្លៃមូលបត្រដែលស្របតាមកិច្ចព្រមព្រៀងនេះនិងមិនត្រូវបានធានាដោយក្រុមហ៊ុនឬ បុគ្គលផ្សេងទៀតឡើយ។

៣.១៦.២ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងសេចក្តីថ្លែងព័ត៌មានហានិភ័យផ្សេងទៀតដែលផ្អែកលើសេវាកម្មដែលបានផ្តល់ឲ្យ ប្រសិនបើមាន។

៣.១៧ ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង

៣.១៧.១ កិច្ចព្រមព្រៀងនេះត្រូវធ្វើជាពីរច្បាប់ដែលមានចុះហត្ថលេខានិងត្រារបស់ក្រុមហ៊ុន ឬស្នាមម្រាមដៃរបស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនត្រូវផ្តល់ឱ្យអតិថិជនមួយច្បាប់ភ្លាមៗនិងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

៣.១៨ បដិវាទកម្ម

៣.១៨.១ ដោយអនុលោមតាមប្រការ ៦ នៃក្រមសីលធម៌វិជ្ជាជីវៈ រាល់លក្ខខណ្ឌនៃកិច្ចព្រមព្រៀងមិនត្រូវលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់។ រាល់លក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះ និង/ឬកិច្ចព្រមព្រៀងផ្សេងទៀត រវាងភាគីទាំងពីរដែលលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់ មិនមានអានុភាពអនុវត្តឡើយ។

៣.១៩ ការជូនដំណឹង

៣.១៩.១ រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឲ្យអតិថិជន ត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬក្រមសីលធម៌វិជ្ជាជីវៈ លើកលែងតែមានសំណើជាលាយលក្ខណ៍អក្សរផ្សេងពីនេះពីអតិថិជន។

៣.១៩.២ អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមៗមកដល់ក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាស័យដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។

៣.២០ ការបញ្ចប់កិច្ចសន្យា

៣.២០.១ ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ៧ ថ្ងៃដល់ភាគីម្ខាងទៀត។

៣.២០.២ ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗ ដែលមានមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ។

៣.២១ កិច្ចព្រមព្រៀងរួម

៣.២១.១ កិច្ចព្រមព្រៀងនេះជាកិច្ចព្រមព្រៀងរួមរវាងភាគីទាំងសងខាង ដែលចែកអំពីការតែងតាំងក្រុមហ៊ុនមូលបត្រធ្វើជាភ្នាក់ងាររបស់អតិថិជននិងលក្ខខណ្ឌនៃការផ្តល់សេវាកម្ម។ រាល់បទបង្ហាញ សេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀត ទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់ រវាងភាគីទាំងសងខាងដែលពាក់ព័ន្ធនឹងបញ្ហានេះ មិនមានអនុភាពអនុវត្តឡើយ។

៣.២២ ការកែប្រែ

៣.២២.១ កិច្ចព្រមព្រៀងនេះអាចកែប្រែនៅពេលមានការយល់ព្រមរវាងភាគីទាំងសងខាង។ នៅពេលមានការធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងនេះក្រុមហ៊ុនមូលបត្រត្រូវកែប្រែកិច្ចព្រមព្រៀងនេះឲ្យស្របតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលបានធ្វើវិសោធនកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឲ្យអតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ។

៣.២៣ ការចាត់តាំង

៣.២៣.១ អតិថិជនព្រមព្រៀងថារាល់សិទ្ធិ និងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវផ្ទេរទៅឲ្យប្រតិសិទ្ធិសកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជនក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃមូលបត្រដែលកើតឡើងដោយប្រតិបត្តិការនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្សីយធន អសមត្ថភាព ដីការតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវចាត់ចែងនូវរាល់ការផ្ទេរមូលបត្រ និងការចុះបញ្ជីនៃការផ្ទេរនោះ ។

៣.២៤ ច្បាប់គ្រប់គ្រង និង យុត្តាធិការ

៣.២៤.១ កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៣.២៤.២ រាល់វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងនេះអាចដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទដែលកំណត់ដោយ ន.ម.ក.។

៣.២៤.៣ ប្រសិនបើវិវាទនោះមិនអាចដោះស្រាយបានតាមនីតិវិធីដែលកំណត់ដោយ ន.ម.ក ក្នុងរយៈពេលសមស្របទេ វិវាទនោះត្រូវដោះស្រាយជាចុងក្រោយតាមរយៈការអាជ្ញាកណ្តាល នៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា (NCAC) ស្របតាមវិធានអាជ្ញាកណ្តាលដែលមានសុពលភាពនៅពេលដាក់សំណើ។ សេចក្តីសម្រេចរបស់អាជ្ញាកណ្តាល គឺជាសេចក្តីសម្រេចចុងក្រោយ និងមានអនុភាពអនុវត្តលើភាគីទាំងអស់។

កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការដួញដូរមូលបត្រនៅលើផ្ទាល CSD

ប្រការ ១៖ សាវតា

១.១ ក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក ជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណឲ្យធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាក្រុមហ៊ុនធានាទិញមូលបត្រ ដោយនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**)។

១.២ លោកអ្នក មានបំណងជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាជួញដូរ និង ផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

១.៣ អនុលោមតាមមាត្រា៥៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រការ៦ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអតិថិជន។

១.៤ ភាគីទាំងពីរត្រូវអនុវត្តតាមលក្ខណ្ឌនៃកិច្ចព្រមព្រៀងនេះដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

ប្រការ ២៖ និយមន័យ

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវឲ្យនិយមន័យដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងបទប្បញ្ញត្តិ ដែលកំណត់ដោយ ន.ម.ក. និងច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។ និយមន័យបន្ថែមខាងក្រោមនឹងត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ៖

២.១ **សាច់ប្រាក់អតិថិជនអាចប្រើប្រាស់បាន៖** សំដៅដល់ប្រាក់ដែលអាចប្រើប្រាស់បាននៅក្នុងគណនីសាច់ប្រាក់អតិថិជន ក្នុងពេលជាក់លាក់មួយ សម្រាប់ការបញ្ជាទិញមូលបត្ររបស់អតិថិជន ដែលយកសមតុល្យក្នុងគណនីសាច់ប្រាក់អតិថិជន ដកចេញនូវរាល់បំណុលអតិថិជនទាំងអស់ ការបញ្ជាទិញពីមុនទាំងអស់របស់អតិថិជន ព្រមទាំងប្រាក់ដែលអតិថិជនបានស្នើដក ឬ ស្នើទូទាត់ទៅតតិយជន ។

២.២ **ពាក្យស្នើសុំបើកគណនីអតិថិជន (Customer Account Opening Form):** សំដៅដល់ ទម្រង់ស្នើសុំបើកគណនី រួមជាមួយឯកសារគាំទ្រ និងព័ត៌មានទាំងអស់ ដែលបានបំពេញ និងផ្តល់ដោយ អតិថិជន ជូន ក្រុមហ៊ុន សម្រាប់គោលបំណងបើក និងរក្សាទុកគណនីរបស់អតិថិជនជាមួយក្រុមហ៊ុន និងការចូលប្រើប្រាស់ សេវាកម្ម ដែលអាចត្រូវបានកែប្រែ ឬធ្វើបច្ចុប្បន្នភាពពីពេលមួយទៅពេលមួយ។

២.៣ **គណនីទូទាត់ក្នុងផ្ទាល CSD (CSD Settlement Account):** សំដៅដល់ គណនីដែលបានកំណត់សម្រាប់ការទូទាត់ប្រតិបត្តិការដែលបានអនុវត្តតាមរយៈវេទិកា CSD រួមទាំង ការទូទាត់ប្រាក់សម្រាប់ការទិញ ការទទួលប្រាក់ពីការលក់ ប្រាក់ចុះឈ្មោះ (subscription monies) ប្រាក់សងត្រឡប់ (redemption proceeds) និងប្រាក់ចំនួនផ្សេងទៀតដែលទាក់ទងនឹងប្រតិបត្តិការសញ្ញាបណ្ណ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីប្រតិបត្តិការដែលអនុវត្តដោយក្រុមហ៊ុន និងវេទិកា CSD ជាធរមាន។

២.៣ **ធនាគារ៖** សំដៅធនាគាពាណិជ្ជដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងការគ្រប់គ្រងនៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

២.៤ **ព័ត៌មានអតិថិជន៖** សំដៅដល់ព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលផ្តល់ឲ្យក្រុមហ៊ុននៅពេលដែលបើកគណនីអតិថិជន ហើយត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។

២.៥ **បំណុលអតិថិជន៖** សំដៅដល់ប្រាក់ដែលអតិថិជនជំពាក់ក្នុងការទូទាត់ទៅបុគ្គលផ្សេងទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ឬច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាអាទិ៍ កម្រៃជើងសា ថ្លៃសេវា លាភការផ្សេងៗ ពន្ធ ឬចំណាយផ្សេងទៀតដែលទាក់ទងនឹងការលក់ ឬការទិញមូលបត្រ និងកម្រៃរដ្ឋបាលដែលទាក់ទងនឹងការធ្វើប្រតិបត្តិការលើគណនីសាច់ប្រាក់អតិថិជន។

២.៦ **បញ្ជាអតិថិជន៖** សំដៅសល់ការបញ្ជាទិញ ឬលក់មូលបត្ររបស់អតិថិជនទៅក្រុមហ៊ុន។

២.៧ **ក្រមសីលធម៌វិជ្ជាជីវៈ៖** សំដៅដល់ប្រកាសស្តីពីក្រមសិលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

២.៨ **អាជ្ញាបណ្ណ៖** សំដៅដល់អាជ្ញាបណ្ណដែលផ្តល់អោយក្រុមហ៊ុនដោយ ន.ម.ក.។

២.៩ **ការជួញដូរមូលបត្រ៖** សំដៅដល់ការជួញដូរមូលបត្រដែលបានចុះបញ្ជីនៅផ្សារមូលបត្រប្រតិស្រុត។

២.១០ **សេវាកម្ម៖** សំដៅដល់ការផ្តល់សេវាជួញដូរ និងផ្តល់ព្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

២.១១ **ប្រតិសិទ្ធិសកល៖** សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធ និងកាតព្វកិច្ចទូទៅពីអ្នកដទៃ។

២.១២ **ប្រតិសិទ្ធិដោយខ្សែក៖** សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធមួយ ឬច្រើនជាកំណត់ផ្អែកតាមមូលហេតុនីមួយៗ។

ប្រការ ៣៖ បទប្បញ្ញត្តិប្រតិបត្តិការ

៣.១ ការជ្រើសរើសក្រុមហ៊ុន

៣.១.១ លោកអ្នកជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាកម្មដោយគោរពតាមលក្ខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ លោកអ្នកព្រមព្រៀងអនុវត្តកាតព្វកិច្ចនានាដែលកើតចេញពីការអនុវត្តអាណត្តិដោយក្រុមហ៊ុន ក្នុងដែនអនុញ្ញាតដែលផ្តល់ដោយអតិថិជនក្រោមកិច្ចព្រមព្រៀងនេះ។

៣.១.២ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការជួញដូរមូលបត្រក្នុងគណនីអតិថិជន ក្នុងនាមអតិថិជនដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជនតាមរយៈកិច្ចព្រមព្រៀងនេះ។

៣.១.៣ ក្រុមហ៊ុនត្រូវធានាថា ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណដែលអនុញ្ញាតអោយផ្តល់សេវាកម្មដល់អតិថិជន។ ក្រុមហ៊ុនត្រូវផ្តល់សេវាកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រដល់អតិថិជនស្របតាមលក្ខខណ្ឌអាជ្ញាបណ្ណដែលបានផ្តល់ដោយអគ្គនាយកនៃ ន. ម. ក. ។

៣.២ ការធ្វើបច្ចុប្បន្នកម្មព័ត៌មាន

៣.២.១ ក្រុមហ៊ុនត្រូវទទួលស្គាល់ និងព្រមព្រៀងថាក្រុមហ៊ុនបានបំពេញទម្រង់ពាក្យស្នើសុំបើកគណនីអតិថិជន ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធរបស់ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ។

៣.២.២ លោកអ្នកត្រូវធានាថា ព័ត៌មានដែលផ្តល់ឲ្យនៅពេលចុះកិច្ចព្រមព្រៀងនេះជាព័ត៌មានពិតប្រាកដ និងត្រឹមត្រូវ។

៣.២.៣ លោកអ្នកត្រូវទទួលស្គាល់ថាក្រុមហ៊ុនផ្តល់សេវាកម្មជូនអតិថិជនដោយផ្អែកលើព័ត៌មានអតិថិជន។ លោកអ្នកយល់ព្រមជូនដំណឹងភ្លាមៗទៅក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរព័ត៌មានជាសារវន្តរបស់អតិថិជន។

៣.២.៤ ក្រុមហ៊ុន ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានទាំងឡាយណាទាក់ទងនឹងក្រុមហ៊ុន នឹងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវព័ត៌មានទាំងនោះដែលកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ។ អនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈក្រុមហ៊ុនត្រូវទទួលស្គាល់ និងយល់ព្រមថាក្រុមហ៊ុនផ្តល់ឲ្យអតិថិជន នូវព័ត៌មានជាលាយលក្ខណ៍អក្សរ មុនពេលអនុវត្តបញ្ជាក្នុងនាមអតិថិជន។ ចំណុចទី ៧ នៃកិច្ចព្រមព្រៀងនេះមិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

៣.៣ ការជួញដូរមូលបត្រ

៣.៣.១ ក្រុមហ៊ុន ត្រូវអនុវត្តការជួញដូរមូលបត្រក្នុងនាមអតិថិជននៅពេលមានបញ្ជាពីអតិថិជនតែប៉ុណ្ណោះ។ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការគណនីឆន្ទានុសិទ្ធិក្នុងនាមអតិថិជន និងមិនអនុញ្ញាតនូវរាល់បញ្ជាពីអតិថិជនឲ្យអនុវត្តការជួញដូរមូលបត្រ ដោយផ្អែកលើមូលដ្ឋានឆន្ទានុសិទ្ធិក្នុងគ្រប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការអនុញ្ញាតពី ន.ម.ក.។

៣.៣.២ អតិថិជនផ្តល់សិទ្ធិឲ្យក្រុមហ៊ុនធ្វើការងារចាំបាច់សមស្របក្នុងនាមអតិថិជន តាមបញ្ជាអតិថិជនដើម្បី៖

ក. បញ្ជូនបញ្ជារបស់អតិថិជន

ខ. ផ្ទេរមូលបត្រដែលត្រូវបានលក់ ឬទិញតាមបញ្ជារបស់អតិថិជន

គ. ជានាថារាល់ការផ្ទេរបានកត់ត្រាត្រឹមត្រូវនៅប្រតិបត្តិការរក្សាទុកមូលបត្រ។

៣.៣.៣ ក្រុមហ៊ុនព្រមព្រៀងចាត់ចែងធ្វើការផ្ទេរមូលបត្រក្នុងនាមអតិថិជន ហើយត្រូវកត់ត្រាការផ្ទេរនោះ ដោយអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ និងស្របតាមវិធាន ប្រព័ន្ធ ព្រមទាំងនីតិវិធីរបស់ប្រតិបត្តិការរក្សាទុកមូលបត្រ និងបទប្បញ្ញាត្តិជាធរមាន។

៣.៣.៤ លោកអ្នកត្រូវទទួលស្គាល់និងព្រមព្រៀងថា៖

ក. ក្រុមហ៊ុនមិនត្រូវទិញមូលបត្រក្នុងនាមអតិថិជនឡើយ លើកលែងតែអតិថិជនផ្តល់ឱ្យក្រុមហ៊ុននូវប្រាក់គ្រប់គ្រាន់ក្នុងការទិញមូលបត្រ និងអតិថិជនយល់ព្រមថា មិនត្រូវធ្វើការដាក់បញ្ជាទិញមូលបត្រ នៅតម្លៃលើសពីបរិមាណប្រាក់អតិថិជនដែលមានឡើយ និង

ខ. ក្រុមហ៊ុនមិនត្រូវលក់ស៊ិតសែល (short sell) ឡើយ និងលោកអ្នកមិនត្រូវដាក់បញ្ជាលក់មូលបត្ររបស់ខ្លួនឡើយ លើកលែងតែមូលបត្រនោះបានចុះបញ្ជីនៅប្រតិបត្តិការរក្សាទុកមូលបត្រក្នុងឈ្មោះរបស់អតិថិជន និងអាចលក់បាន។

៣.៣.៥ អតិថិជនព្រមព្រៀងតាមការកំណត់នៃបញ្ជារបស់ខ្លួន ហើយត្រូវទទួលស្គាល់ និងយល់ព្រមថាបញ្ជារបស់អតិថិជននិងមិនត្រូវបានលុបចោល ឬផ្លាស់ប្តូរបន្ទាប់ពីបានអនុវត្តឡើយ។ បញ្ជារបស់អតិថិជនមិនអាចត្រូវបានលុបចោល ឬផ្លាស់ប្តូរ មុនពេលអនុវត្តតាមបញ្ជារបស់អតិថិជន លើកលែងតែអតិថិជនបានជូនដំណឹងដល់ក្រុមហ៊ុននូវការលុបចោលឬការផ្លាស់ប្តូរនោះស្របតាមការតម្រូវរបស់ក្រុមហ៊ុន។ ចំណុចទី ៨ នៃកិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

៣.៤ វិធីសាស្ត្រក្នុងការដាក់បញ្ជា

៣.៤.១ លោកអ្នកអាចដាក់បញ្ជាដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម៖

ក. ជាលាយលក្ខណ៍អក្សរ ឬ អ៊ីម៉ែល

ខ. ប្រព័ន្ធជួញដូរចល័ត (CSD Web/Desktop)

គ. ប្រព័ន្ធជួញដូរចល័ត (CSD Mobile)

ឃ. តាមរយៈទូរស័ព្ទ

ង. តាមវិធីទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀតដែលកំណត់ដោយ ន.ម.ក.។

៣.៤.២ បញ្ជារបស់លោកអ្នកត្រូវបង្ហាញព័ត៌មានទាក់ទងនឹងការជួញដូរមូលបត្ររួមមាន ឈ្មោះមូលបត្រ ប្រភេទមូលបត្រ បរិមាណមូលបត្រ ថ្លៃមូលបត្រ និងកាលរិចួទ។ ក្រុមហ៊ុនត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមអេឡិចត្រូនិច ដើម្បីធ្វើជាភស្តុតាងនៃការដាក់បញ្ជា។

៣.៥ កាតព្វកិច្ចរបស់ក្រុមហ៊ុនពាក់ពាន់នឹការដាក់បញ្ជា

៣.៥.១ ក្រុមហ៊ុន ត្រូវជានាឲ្យមាននូវយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទទួលបញ្ជាពីអតិថិជនតាមរយៈទូរស័ព្ទ ឬអ៊ីម៉ែល។

៣.៥.២ ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មានដល់អតិថិជនអំពីហានិភ័យផ្សេងៗ ដែលអាចកើតមានពេលដាក់បញ្ជាតាមរយៈទូរសព្ទ អ៊ីម៉ែល និងប្រព័ន្ធជួញដូរចល័ត (CSD Platform) និង ត្រូវទទួលខុសត្រូវលើហានិភ័យនៃការអាក់រអួលប្រព័ន្ធទូរស័ព្ទ ឬអ៊ីនធើណែតផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្នុងពេលទទួលបញ្ជារបស់អតិថិជនតាមរយៈទូរស័ព្ទ ឬ អ៊ីម៉ែល។

៣.៥.៣ ក្រុមហ៊ុន ជានាកាត់បន្ថយជាអតិបរមា នូវហានិភ័យដែលកើតឡើងពាក់ព័ន្ធនឹងការបញ្ជាតាមរយៈទូរសព្ទ ឬអ៊ីម៉ែល។

៣.៥.៤ ក្រុមហ៊ុន ត្រូវជូនដំណឹងភ្លាមដល់អតិថិជនក្នុងករណីក្រុមហ៊ុនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជា។

៣.៦ កាតព្វកិច្ចរបស់លោកអ្នកពាក់ព័ន្ធនឹងការដាក់បញ្ជា

៣.៦.១ លោកអ្នក ត្រូវទទួលស្គាល់ថាបានសិក្សា និងយល់ដឹងច្បាស់លាស់អំពីហានិភ័យដែលអាចកើតមានឡើងក្នុងការដាក់បញ្ជាតាមវិធីសាស្ត្រដែលលោកអ្នកបានជ្រើសរើស។

៣.៦.២ លោកអ្នក ត្រូវទទួលស្គាល់ថាលេខទូរស័ព្ទសម្រាប់ការហៅទូរស័ព្ទ និង/ឬ អាស័យដ្ឋានអ៊ីម៉ែលសម្រាប់ដាក់បញ្ជាដែលបានផ្តល់ជូនក្រុមហ៊ុន ពិតជាត្រឹមត្រូវប្រាកដមែន ហើយអតិថិជនទទួលខុសត្រូវលើរាល់ការដាក់បញ្ជាតាមរយៈទូរស័ព្ទ អាសយដ្ឋានអ៊ីម៉ែល និងតាមប្រព័ន្ធជួញដូរចល័ត (CSX TRADE)

៣.៦.៣ លោកអ្នក យល់ព្រមឲ្យក្រុមហ៊ុនថតសម្លេងទុកជាភស្តុតាងពេលអតិថិជនដាក់បញ្ជា ឬពេលក្រុមហ៊ុនជូនដំណឹងអំពីព័ត៌មាននៃការអនុវត្តបញ្ជាតាមរយៈការហៅទូរស័ព្ទ។

៣.៦.៤ លោកអ្នក ត្រូវជូនដំណឹងភ្លាមដល់ក្រុមហ៊ុនក្នុងករណីអតិថិជនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជា បានប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជា។

៣.៧ ការបដិសេធទទួលបញ្ជា

៣.៧.១ ក្រុមហ៊ុន មិនត្រូវអនុវត្តតាមបញ្ជាអតិថិជនទេ ប្រសិនបើការអនុវត្តបញ្ជាអតិថិជននោះផ្ទុយនឹងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ឬលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ ក្រុមហ៊ុនមិនទទួលខុសត្រូវលើការខាតបង់ថ្លៃដើម ឬការចំណាយរបស់អតិថិជនឡើយ ដែលបណ្តាលមកពីការបដិសេធរបស់ក្រុមហ៊ុនក្នុងការអនុវត្តតាមបញ្ជារបស់អតិថិជន។

៣.៧.២ ក្រុមហ៊ុន ត្រូវជូនដំណឹងភ្លាមៗដល់អតិថិជនជាលាយលក្ខណ៍អក្សរក្នុងករណីមានការបដិសេធដូចមានចែងក្នុងកថាខណ្ឌទីមួយ ឬមានកំហុសឆ្គងក្នុងការអនុវត្តបញ្ជារបស់អតិថិជន ឬការអនុវត្តបញ្ជាដោយអនុលោមតាមលក្ខខណ្ឌនៃបញ្ជាអតិថិជន។

៣.៨ ការជូនដំណឹងការជួញដូរមូលបត្រ

៣.៨.១ ក្រុមហ៊ុនត្រូវជូនដំណឹងដល់អតិថិជននៅរាល់ប្រតិបត្តិការមូលបត្រដែលធ្វើក្នុងនាមអតិថិជនដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ អតិថិជនយល់ព្រមពិនិត្យយ៉ាងយកចិត្តទុកដាក់នូវការជូនដំណឹងនោះ ហើយជូនដំណឹងទៅក្រុមហ៊ុនវិញភ្លាមនូវភាពខុសគ្នារវាងកំណត់ត្រារបស់អតិថិជន និងព័ត៌មានដែលបង្ហាញក្នុងសេចក្តីជូនដំណឹង។

៣.៩ គណនីសាច់ប្រាក់អតិថិជន

៣.៩.១ លោកអ្នកផ្តល់សិទ្ធិដល់ក្រុមហ៊ុនចំពោះ៖

ក. ការដាក់តម្កល់ប្រាក់ដែលទទួលបានពីអតិថិជន ឬក្នុងនាមអតិថិជនទៅក្នុងគណនីសាច់ប្រាក់អតិថិជនដែលពាក់ព័ន្ធនឹងអតិថិជន។

ខ. ការទទួលប្រាក់ពីការលក់មូលបត្រក្នុងនាមអតិថិជន តាមបញ្ជាចូលក្នុងគណនីសាច់ប្រាក់អតិថិជន។

គ. ការទូទាត់ចេញពីគណនីសាច់ប្រាក់អតិថិជនសម្រាប់ការទិញមូលបត្រក្នុងនាមអតិថិជន តាមបញ្ជារបស់អតិថិជន។

ឃ. ការទូទាត់សងបំណុលអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រពីគណនីសាច់ប្រាក់អតិថិជន។

ង. ការទូទាត់ផ្សេងៗពីគណនីសាច់ប្រាក់អតិថិជនដែលតម្រូវដោយច្បាប់និង

ច. ការដាក់ប្រាក់ចូលនឹងការដកប្រាក់ចេញពីគណនីសាច់ប្រាក់អតិថិជននៅពេលមានបញ្ជាអតិថិជន ឬការណែនាំជាលាយលក្ខណ៍អក្សរពីអតិថិជន។

៣.៩.២ លោកអ្នកមានសិទ្ធិទទួលរាល់ចំណូលការប្រាក់ដែលកើតមានក្នុងគណនីអតិថិជន។

៣.១០ ផលប្រយោជន៍ និងទំនាក់ទំនង

៣.១០.១ ក្រុមហ៊ុន ត្រូវបញ្ជាក់នូវរាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ក្រុមហ៊ុន ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រក្នុងកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែកដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

៣.១១ ការតវ៉ា

៣.១១.១ ករណីក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ ឬភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរដោយត្រូវមានបញ្ជាក់ឈ្មោះនិងព័ត៌មានលម្អិតនៃបុគ្គលដោះស្រាយការតវ៉ារបស់ក្រុមហ៊ុន។

៣.១១.២ ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយវិវាទរបស់អតិថិជនក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃនៅថ្ងៃធ្វើការបន្ទាប់ពីបានទទួលការតវ៉ា។

៣.១១.៣ ក្នុងករណីដែលពាក្យបណ្តឹងមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃធ្វើការ ដោយសារភាពស្មុគស្មាញ ឬស្ថានការណ៍ផ្សេងទៀត ក្រុមហ៊ុននឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ លោកអ្នក អំពីមូលហេតុនៃការពន្យារពេល ស្ថានភាពនៃពាក្យបណ្តឹង និងរយៈពេលដែលរំពឹងទុកសម្រាប់ការដោះស្រាយ។ ក្រុមហ៊ុននឹងបន្តដោះស្រាយពាក្យបណ្តឹងនោះដោយឆាប់រហ័សនិងដោយសុចរិតភាព រហូតដល់មានការដោះស្រាយចុងក្រោយ។

៣.១២ តំណាងរបស់អតិថិជន

៣.១២.១ លោកអ្នកអាចជ្រើសរើសបុគ្គលក្រៅពីក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រធ្វើជាតំណាង តាមរយៈលិខិតផ្ទេរសិទ្ធិ ឬការអនុញ្ញាតដោយច្បាប់ដើម្បីដាក់បញ្ជាទិញ-លក់ ឬបញ្ជាផ្សេងទៀតក្នុងនាមអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ នៅពេលចុះកិច្ចព្រមព្រៀងនេះ អតិថិជនដែលមានបំណងជ្រើសរើសបុគ្គលដែលធ្វើជាអ្នកតំណាងត្រូវបញ្ជាក់ក្នុងកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែក។

៣.១២.២ មុនទទួលបញ្ជាពីអ្នកតំណាងរបស់អតិថិជន ក្រុមហ៊ុនត្រូវតម្រូវឲ្យអតិថិជនផ្តល់ឲ្យក្រុមហ៊ុននៅឯកសារដើម ឬថតចម្លង មានបញ្ជាក់ត្រឹមត្រូវនៃការអនុញ្ញាតនូវការជ្រើសរើសអ្នកតំណាង។

៣.១២.៣ លោកអ្នក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាម ដល់ក្រុមហ៊ុនពីការដកហូតសិទ្ធិរបស់អ្នកតំណាង។ ក្រុមហ៊ុនអាចធ្វើប្រតិបត្តិការដែលទទួលបានពីអ្នកតំណាង តាមបញ្ជាទិញលក់មូលបត្រ ឬបញ្ជាផ្សេងទៀតលើកលែងតែមានការជូនដំណឹងផ្សេងទៀតពីអតិថិជន។

៣.១៣ ការរក្សាភាពសម្ងាត់

៣.១៣.១ ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងការអនុវត្តសេវាកម្មស្របតាមកិច្ចព្រមព្រៀងនេះទៅឲ្យបុគ្គលណាផ្សេងឡើយ លើកលែងតែមានករណីណាមួយដូចខាងក្រោម៖

ក. មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលនូវព័ត៌មានសម្ងាត់។

ខ. មានការស្នើសុំពី ន.ម.ក ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

គ. មានការតម្រូវដោយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

៣.១៤ សេចក្តីថ្លែងព័ត៌មានហានិភ័យ

៣.១៤.១ លោកអ្នកត្រូវទទួលស្គាល់ថាថ្លៃមូលបត្រអាចប្រែប្រួលឡើង ឬចុះ ហើយព័ត៌មានដែលត្រូវបានផ្តល់ឲ្យអំពីចំណូលនៃការវិនិយោគ ឬថ្លៃមូលបត្រដែលស្របតាមកិច្ចព្រមព្រៀងនេះនិងមិនត្រូវបានធានាដោយក្រុមហ៊ុនឬ បុគ្គលផ្សេងទៀតឡើយ។

៣.១៤.២ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងសេចក្តីថ្លែងព័ត៌មានហានិភ័យផ្សេងទៀតដែលផ្អែកលើសេវាកម្មដែលបានផ្តល់ឲ្យ ប្រសិនបើមាន។

៣.១៥ ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង

៣.១៥.១ កិច្ចព្រមព្រៀងនេះត្រូវធ្វើជាពីរច្បាប់ដែលមានចុះហត្ថលេខានិងត្រារបស់ក្រុមហ៊ុន ឬស្នាមម្រាមដៃរបស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនត្រូវផ្តល់ឱ្យអតិថិជនមួយច្បាប់ភ្លាមៗនិងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

៣.១៦ បដិវាទកម្ម

៣.១៦.១ ដោយអនុលោមតាមប្រការ ៦ នៃក្រមសីលធម៌វិជ្ជាជីវៈ រាល់លក្ខខណ្ឌនៃកិច្ចព្រមព្រៀងមិនត្រូវលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់។ រាល់លក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះ និង/ឬ កិច្ចព្រមព្រៀងផ្សេងទៀត រវាងភាគីទាំងពីរដែលលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់ មិនមានអានុភាពអនុវត្តឡើយ។

៣.១៧ ការជូនដំណឹង

៣.១៧.១ រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឲ្យអតិថិជន ត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬក្រមសីលធម៌វិជ្ជាជីវៈ លើកលែងតែមានសំណើជាលាយលក្ខណ៍អក្សរផ្សេងពីនេះពីអតិថិជន។

៣.១៧.២ អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមៗមកដល់ក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាស័យដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។

៣.១៨ ការបញ្ចប់កិច្ចសន្យា

៣.១៨.១ ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃដល់ភាគីម្ខាងទៀត។

៣.១៨.២ ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗ ដែលមានមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ។

៣.១៩ កិច្ចព្រមព្រៀងរួម

៣.១៩.១ កិច្ចព្រមព្រៀងនេះជាកិច្ចព្រមព្រៀងរួមរវាងភាគីទាំងសងខាង ដែលចែកអំពីការតែងតាំងក្រុមហ៊ុនមូលបត្រធ្វើជាភ្នាក់ងាររបស់អតិថិជននិងលក្ខខណ្ឌនៃការផ្តល់សេវាកម្ម។ រាល់បទបង្ហាញ សេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀត ទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់ រវាងភាគីទាំងសងខាងដែលពាក់ព័ន្ធនឹងបញ្ហានេះ មិនមានអនុភាពអនុវត្តឡើយ។

៣.២០ ការកែប្រែ

៣.២០.១ កិច្ចព្រមព្រៀងនេះអាចកែប្រែនៅពេលមានការយល់ព្រមជាលាយលក្ខណ៍អក្សរពាក់ព័ន្ធទាំងសងខាង។ នៅពេលមានការធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលផ្តុំយទៅនឹងកិច្ចព្រមព្រៀងនេះក្រុមហ៊ុនមូលបត្រត្រូវកែប្រែកិច្ចព្រមព្រៀងនេះឲ្យស្របតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលបានធ្វើវិសោធនកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឲ្យអតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ។

៣.២១ ការចាត់តាំង

៣.២១.១ អតិថិជនព្រមព្រៀងថារាល់សិទ្ធិ និងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវផ្ទេរទៅឲ្យប្រតិសិទ្ធិសកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជនក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃមូលបត្រដែលកើតឡើងដោយប្រតិបត្តិការនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្ស័យធន អសមត្ថភាព ដីការតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវចាត់ចែងនូវរាល់ការផ្ទេរមូលបត្រ និងការចុះបញ្ជីនៃការផ្ទេរនោះ ។

៣.២២ ច្បាប់គ្រប់គ្រង និង យុត្តាធិការ

៣.២២.១ កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៣.២២.២ រាល់វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងនេះអាចដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទដែលកំណត់ដោយ ន.ម.ក.។

៣.២២.៣ ប្រសិនបើវិវាទនោះមិនអាចដោះស្រាយបានតាមនីតិវិធីដែលកំណត់ដោយ ន.ម.ក ក្នុងរយៈពេលសមស្របទេ វិវាទនោះត្រូវដោះស្រាយជាចុងក្រោយតាមរយៈការអាជ្ញាកណ្តាល នៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា (NCAC) ស្របតាមវិធានអាជ្ញាកណ្តាលដែលមានសុពលភាពនៅពេលដាក់សំណើ។ សេចក្តីសម្រេចរបស់អាជ្ញាកណ្តាល គឺជាសេចក្តីសម្រេចចុងក្រោយ និងមានអនុភាពអនុវត្តលើភាគីទាំងអស់។

កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការជួញដូរមូលបត្ររដ្ឋនៅលើផ្ទាល NBC

ប្រការ ១៖ សាវតា

១.១ ក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក ជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណឲ្យធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាក្រុមហ៊ុនធានាទិញមូលបត្រ ដោយនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.)។

១.២ លោកអ្នក មានបំណងជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាជួញដូរ និង ផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

១.៣ អនុលោមតាមមាត្រា៥៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រការ៦ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអតិថិជន។

១.៤ ភាគីទាំងពីរត្រូវអនុវត្តតាមលក្ខណ្ឌនៃកិច្ចព្រមព្រៀងនេះដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

ប្រការ ២៖ និយមន័យ

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវឲ្យនិយមន័យដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងបទប្បញ្ញត្តិ ដែលកំណត់ដោយ ន.ម.ក. និងច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។ និយមន័យបន្ថែមខាងក្រោមនឹងត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ៖

២.១ **ធនាគារ៖** សំដៅធនាគាពាណិជ្ជដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងការគ្រប់គ្រងនៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។

២.២ **ប្រាក់ទូទាត់ការដេញថ្លៃ៖** សំដៅដល់ចំនួនទឹកប្រាក់ដែលត្រូវទូទាត់សម្រាប់ការដេញថ្លៃ ដែលអតិថិជនបានដាក់ស្នើ ដែលត្រូវមានចំនួន១០០% នៃទឹកប្រាក់សរុបនៃបរិមាណស្នើសុំដេញថ្លៃ គុណនឹង តម្លៃដែលបានដេញថ្លៃជោគជ័យ/មួយឯកតា ដែលបានដេញថ្លៃក្នុងពាក្យស្នើសុំ។ ទឹកប្រាក់ដែលដាក់តម្កល់ នឹងមិនមានការប្រាក់ទេ លើកលែងតែមានការបញ្ជាក់ច្បាស់លាស់ពី ន.ម.ក.។

២.៣ **ការដេញថ្លៃរបស់អតិថិជន៖** សំដៅដល់ការដេញថ្លៃដែលអតិថិជនបានដាក់ស្នើទៅក្រុមហ៊ុន។

២.៤ **ព័ត៌មានអតិថិជន៖** សំដៅដល់ព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលផ្តល់ឱ្យក្រុមហ៊ុននៅពេលដែលបើកគណនីអតិថិជន ហើយត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។

២.៥ **បញ្ជាអតិថិជន៖** សំដៅដល់ការបញ្ជាទិញ ឬលក់មូលបត្ររបស់អតិថិជនទៅក្រុមហ៊ុន។

២.៦ **ពាក្យស្នើសុំបើកគណនីអតិថិជន (Customer Account Opening Form):** សំដៅដល់ ទម្រង់ស្នើសុំបើកគណនី រួមជាមួយឯកសារគាំទ្រ និងព័ត៌មានទាំងអស់ ដែលបានបំពេញ និងផ្តល់ដោយ អតិថិជន ជូន ក្រុមហ៊ុន សម្រាប់គោលបំណងបើក និងរក្សាទុកគណនីរបស់អតិថិជនជាមួយក្រុមហ៊ុន និងការចូលប្រើប្រាស់ សេវាកម្ម ដែលអាចត្រូវបានកែប្រែ ឬធ្វើបច្ចុប្បន្នភាពពីពេលមួយទៅពេលមួយ។

២.៧ **ក្រមសីលធម៌វិជ្ជាជីវៈ៖** សំដៅដល់ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

២.៨ **អាជ្ញាបណ្ណ៖** សំដៅដល់អាជ្ញាបណ្ណដែលផ្តល់អោយក្រុមហ៊ុនដោយ ន.ម.ក.។

២.៩ **មូលបត្របំណុលរដ្ឋ៖** សំដៅដល់មូលបត្របំណុលរដ្ឋដែលបោះផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា។

២.១០ **ការជួញដូរមូលបត្រ៖** សំដៅដល់ការជួញដូរមូលបត្របំណុលរដ្ឋដែលបានចុះបញ្ជីនៅ ផ្លេតហ្វម NBC និងផ្សារមូលបត្រប្រតិស្រុត។

២.១១ **ផ្លេតហ្វម NBC៖** សំដៅដល់ផ្លេតហ្វមរបស់ធនាគារជាតិនៃកម្ពុជា ដែលប្រើប្រាស់សម្រាប់ដេញថ្លៃ និងជួញដូរមូលបត្របំណុលរដ្ឋ។

២.១២ **សេវាកម្ម៖** សំដៅដល់ការផ្តល់សេវាដេញថ្លៃ ជួញដូរ និងផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្របំណុលរដ្ឋ។

២.១៣ **ប្រតិសិទ្ធិសកល៖** សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធ និងកាតព្វកិច្ចទូទៅពីអ្នកដទៃ។

២.១៤ **ប្រតិសិទ្ធិដោយឡែក៖** សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធមួយ ឬច្រើនជាកំណត់ផ្អែកតាមមូលហេតុនីមួយៗ។

ប្រការ ៣៖ បទប្បញ្ញត្តិប្រតិបត្តិការ

៣.១ ការជ្រើសរើសក្រុមហ៊ុន

៣.១.១ លោកអ្នកជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាកម្មដោយគោរពតាមលក្ខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ លោកអ្នកព្រមព្រៀងអនុវត្តកាតព្វកិច្ចនានាដែលកើតចេញពីការអនុវត្តអាណត្តិដោយក្រុមហ៊ុន ក្នុងដែនអនុញ្ញាតដែលផ្តល់ដោយអតិថិជនក្រោមកិច្ចព្រមព្រៀងនេះ។

៣.១.២ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការជួញដូរមូលបត្រក្នុងគណនីអតិថិជន ក្នុងនាមអតិថិជនដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជនតាមរយៈកិច្ចព្រមព្រៀងនេះ។

៣.១.៣ ក្រុមហ៊ុនត្រូវធានាថា ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណដែលអនុញ្ញាតអោយផ្តល់សេវាកម្មដល់អតិថិជន។ ក្រុមហ៊ុនត្រូវផ្តល់សេវាកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រដល់អតិថិជនស្របតាមលក្ខខណ្ឌអាជ្ញាបណ្ណដែលបានផ្តល់ដោយអគ្គនាយកនៃ ន.ម.ក.។

៣.២ ការធ្វើបច្ចុប្បន្នកម្មព័ត៌មាន

៣.២.១ ក្រុមហ៊ុនត្រូវទទួលស្គាល់ និងព្រមព្រៀងថាក្រុមហ៊ុនបានបំពេញទម្រង់ពាក្យស្នើសុំបើកគណនីអតិថិជន ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធរបស់ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ។

៣.២.២ លោកអ្នកត្រូវធានាថា ព័ត៌មានដែលផ្តល់ឱ្យនៅពេលចុះកិច្ចព្រមព្រៀងនេះជាព័ត៌មានពិតប្រាកដ និងត្រឹមត្រូវ។

៣.២.៣ លោកអ្នកត្រូវទទួលស្គាល់ថាក្រុមហ៊ុនផ្តល់សេវាកម្មជូនអតិថិជនដោយផ្អែកលើព័ត៌មានអតិថិជន។ លោកអ្នកយល់ព្រមជូនដំណឹងភ្លាមៗទៅក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរព័ត៌មានជាសារវន្តរបស់លោកអ្នក។

៣.២.៤ ក្រុមហ៊ុន ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានទាំងឡាយណាទាក់ទងនឹងក្រុមហ៊ុន នឹងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវព័ត៌មានទាំងនោះដែលកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ។ អនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈក្រុមហ៊ុនត្រូវទទួលស្គាល់ និងយល់ព្រមថាក្រុមហ៊ុនផ្តល់ឱ្យអតិថិជន នូវព័ត៌មានជាលាយលក្ខណ៍អក្សរ មុនពេលអនុវត្តបញ្ជាក្នុងនាមអតិថិជន។

៣.៣ ការដេញថ្លៃមូលបត្ររដ្ឋ

៣.៣.១ ក្រុមហ៊ុន ត្រូវអនុវត្តការដេញថ្លៃមូលបត្របំណុលរដ្ឋក្នុងនាមអតិថិជននៅពេលមានការដេញថ្លៃពីអតិថិជនតែប៉ុណ្ណោះ។ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការគណនីឆន្ទានុសិទ្ធិក្នុងនាមអតិថិជន និងមិនអនុញ្ញាតនូវរាល់ការដេញថ្លៃពីអតិថិជនឱ្យអនុវត្តការដេញថ្លៃមូលបត្ររដ្ឋ ដោយផ្អែកលើមូលដ្ឋានឆន្ទានុសិទ្ធិក្នុងគ្រប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការអនុញ្ញាតពី ន.ម.ក.។

៣.៣.២ អតិថិជនផ្តល់សិទ្ធិឱ្យក្រុមហ៊ុនធ្វើការងារចាំបាច់សមស្របក្នុងនាមអតិថិជន តាមការដេញថ្លៃពីអតិថិជនដើម្បី៖

ក. បញ្ជូនការដេញថ្លៃពីអតិថិជន

ខ. ផ្ទេរមូលបត្របំណុលរដ្ឋដែលត្រូវបានដេញថ្លៃបានជោគជ័យដោយអតិថិជន និង

គ. ធានាថារាល់ការផ្ទេរបានកត់ត្រាត្រឹមត្រូវនៅថ្នាល NBC។

៣.៣.៣ ក្រុមហ៊ុនព្រមព្រៀងចាត់ចែងធ្វើការផ្ទេរមូលបត្របំណុលរដ្ឋក្នុងនាមអតិថិជន ហើយត្រូវកត់ត្រាការផ្ទេរនោះ ដោយអនុលោមតាមក្រមសិលធម៌វិជ្ជាជីវៈ និងស្របតាមវិធាន ប្រព័ន្ធ ព្រមទាំងនីតិវិធីរបស់ថ្នាល NBC និងបទប្បញ្ញាត្តិជាធរមាន។

៣.៣.៤ ក្រុមហ៊ុន និងអតិថិជនត្រូវទទួលស្គាល់និងព្រមព្រៀងថា៖

ក. ក្រុមហ៊ុនមិនត្រូវទូទាត់មូលបត្របំណុលរដ្ឋក្នុងនាមអតិថិជនឡើយ លើកលែងតែអតិថិជនផ្តល់ឱ្យក្រុមហ៊ុននូវប្រាក់ទូទាត់ការជេញថ្លៃ ក្នុងការជេញថ្លៃមូលបត្របំណុលរដ្ឋត្រឹមយ៉ាងយូរ ថ្ងៃជេញថ្លៃមូលបត្ររដ្ឋបូកមួយថ្ងៃ (T+1) ដូចដែលបានចែងក្នុងពាក្យស្នើសុំជេញថ្លៃមូលបត្ររដ្ឋនីមួយៗ ដែលបានដាក់ស្នើដោយអតិថិជន និងអតិថិជន យល់ព្រមថា មិនត្រូវធ្វើការដាក់ការជេញថ្លៃមូលបត្របំណុលរដ្ឋ នៅតម្លៃលើសពីបរិមាណប្រាក់ទូទាត់ការជេញថ្លៃ អតិថិជនដែលមានឡើយ និង

ខ. ប្រសិនបើអតិថិជន មិនបានដាក់បញ្ចូលប្រាក់ទូទាត់ការជេញថ្លៃគ្រប់គ្រាន់ត្រឹមថ្ងៃទូទាត់ដែលបានចែងក្នុងពាក្យស្នើសុំជេញថ្លៃមូលបត្ររដ្ឋនីមួយៗទេ អតិថិជន យល់ព្រមបង់ថ្លៃពិន័យដែលអាចនឹងកំណត់ដោយអាជ្ញាធរពាក់ព័ន្ធ និង

គ. ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការជេញថ្លៃមិនជោគជ័យ ដែលកើតឡើងពេលដំណើរការជេញថ្លៃមូលបត្ររដ្ឋ។

៣.៤ ការជួញដូរមូលបត្របំណុលរដ្ឋ

៣.៤.១ ក្រុមហ៊ុន ត្រូវអនុវត្តការជួញដូរមូលបត្របំណុលរដ្ឋក្នុងនាមអតិថិជននៅពេលមានបញ្ជាពីអតិថិជនតែប៉ុណ្ណោះ។ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការគណនីឆន្ទានុសិទ្ធិក្នុងនាមអតិថិជន និងមិនអនុញ្ញាតនូវរាល់បញ្ជាពីអតិថិជនឱ្យអនុវត្តការជួញដូរមូលបត្រ ដោយផ្អែកលើមូលដ្ឋានឆន្ទានុសិទ្ធិក្នុងគ្រប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការអនុញ្ញាតពី ន.ម.ក.។

៣.៤.២ លោកអ្នកផ្តល់សិទ្ធិឱ្យក្រុមហ៊ុនធ្វើការងារចាំបាច់សមស្របក្នុងនាមអតិថិជន តាមបញ្ជាអតិថិជនដើម្បី៖

ក. បញ្ជូនបញ្ជារបស់អតិថិជន

ខ. ផ្ទេរមូលបត្របំណុលរដ្ឋដែលត្រូវបានលក់ ឬទិញតាមបញ្ជារបស់អតិថិជន

គ. ធានាថារាល់ការផ្ទេរបានកត់ត្រាត្រឹមត្រូវនៅថ្នាល NBC។

៣.៤.៣ ក្រុមហ៊ុនព្រមព្រៀងចាត់ចែងធ្វើការផ្ទេរមូលបត្របំណុលរដ្ឋក្នុងនាមអតិថិជន ហើយត្រូវកត់ត្រាការផ្ទេរនោះ ដោយអនុលោមតាមក្រមសិលធម៌វិជ្ជាជីវៈ និងស្របតាមវិធាន ប្រព័ន្ធ ព្រមទាំងនីតិវិធីរបស់ថ្នាល NBC និងបទប្បញ្ញាត្តិជាធរមាន។

៣.៤.៤ លោកអ្នកត្រូវទទួលស្គាល់និងព្រមព្រៀងថា៖

ក. ក្រុមហ៊ុនមិនត្រូវទិញមូលបត្របំណុលរដ្ឋក្នុងនាមអតិថិជនឡើយ លើកលែងតែអតិថិជនផ្តល់ឱ្យក្រុមហ៊ុននូវប្រាក់អតិថិជនគ្រប់គ្រាន់ក្នុងការទិញមូលបត្របំណុលរដ្ឋ និងអតិថិជន យល់ព្រមថា មិនត្រូវធ្វើការដាក់បញ្ជាទិញមូលបត្របំណុលរដ្ឋ នៅតម្លៃលើសពីបរិមាណប្រាក់អតិថិជនដែលមានឡើយ និង

ខ. ក្រុមហ៊ុនមិនត្រូវលក់ស៊ិតសែល (short sell) ឡើយ និងអតិថិជនមិនត្រូវដាក់បញ្ជាលក់មូលបត្ររបស់ខ្លួនឡើយ លើកលែងតែមូលបត្រនោះបានចុះបញ្ជីនៅថ្នាល NBC ក្នុងឈ្មោះរបស់អតិថិជន និងអាចលក់បាន។

៣.៤.៥ លោកអ្នកព្រមព្រៀងតាមការកំណត់នៃបញ្ជារបស់ខ្លួន ហើយត្រូវទទួលស្គាល់ និងយល់ព្រមថាបញ្ជារបស់អតិថិជននិងមិនត្រូវបានលុបចោល ឬផ្លាស់ប្តូរបន្ទាប់ពីបានអនុវត្តឡើយ។ បញ្ជារបស់អតិថិជនមិនអាចត្រូវបានលុបចោល ឬផ្លាស់ប្តូរ មុនពេលអនុវត្តតាមបញ្ជារបស់អតិថិជន លើកលែងតែអតិថិជនបានជូនដំណឹងដល់ក្រុមហ៊ុននូវការលុបចោលឬការផ្លាស់ប្តូរនោះស្របតាមការតម្រូវរបស់ក្រុមហ៊ុន។

៣.៥ វិធីសាស្ត្រក្នុងការជេញថ្លៃ និងដាក់បញ្ជា

៣.៥.១ លោកអ្នកអាចដាក់បញ្ជាដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម៖

ក. ជាលាយលក្ខណ៍អក្សរ ឬ អ៊ីម៉ែល

ខ. តាមរយៈទូរស័ព្ទ

គ. តាមវិធីទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀតដែលកំណត់ដោយ ន.ម.ក.។

៣.៥.២ បញ្ជាអតិថិជនត្រូវបង្ហាញព័ត៌មានទាក់ទងនឹងការជួញដូរមូលបត្របំណុលរដ្ឋ រួមមាន ឈ្មោះមូលបត្រ ប្រភេទមូលបត្រ បរិមាណមូលបត្រ ថ្លៃមូលបត្រ និងកាលវិភាគទេ។ ក្រុមហ៊ុនត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមអេឡិចត្រូនិចដើម្បីធ្វើជាភស្តុតាងនៃការដាក់បញ្ជា។

៣.៦ កាតព្វកិច្ចរបស់ក្រុមហ៊ុនពាក់ព័ន្ធនឹងការដាក់បញ្ជា

៣.៦.១ ក្រុមហ៊ុន ត្រូវធានាឱ្យមាននូវយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទទួលបញ្ជាពីអតិថិជនតាមរយៈទូរស័ព្ទ ឬអ៊ីម៉ែល។

៣.៦.២ ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មានដល់អតិថិជនអំពីហានិភ័យផ្សេងៗ ដែលអាចកើតមានពេលដាក់បញ្ជាតាមរយៈទូរសព្ទ និងអ៊ីម៉ែល និងត្រូវទទួលខុសត្រូវលើហានិភ័យនៃការអាក់រអួលប្រព័ន្ធទូរស័ព្ទ ឬអ៊ីនធើណេតផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្នុងពេលទទួលបញ្ជារបស់អតិថិជនតាមរយៈទូរស័ព្ទ ឬ អ៊ីម៉ែល។

៣.៦.៣ ក្រុមហ៊ុន ធានាកាត់បន្ថយជាអតិបរមា នូវហានិភ័យដែលកើតឡើងពាក់ព័ន្ធនឹងការបញ្ជាតាមរយៈទូរសព្ទ ឬអ៊ីម៉ែល។

៣.៦.៤ ក្រុមហ៊ុន ត្រូវជូនដំណឹងភ្លាមដល់អតិថិជនក្នុងករណីក្រុមហ៊ុនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជា។

៣.៧ កាតព្វកិច្ចរបស់អតិថិជនពាក់ព័ន្ធនឹងការដាក់បញ្ជា

៣.៧.១ លោកអ្នក ត្រូវទទួលស្គាល់ថាខ្លួនបានសិក្សា និងយល់ដឹងច្បាស់លាស់អំពីហានិភ័យដែលអាចកើតមានឡើងក្នុងការដាក់បញ្ជាតាមវិធីសាស្ត្រដែលអតិថិជនបានជ្រើសរើស។

៣.៧.២ លោកអ្នក ត្រូវទទួលស្គាល់ថាលេខទូរស័ព្ទសម្រាប់ការហៅទូរស័ព្ទ និង/ឬ អាស័យដ្ឋាន អ៊ីម៉ែលសម្រាប់ដាក់បញ្ជាដែលបានផ្តល់ជូនក្រុមហ៊ុន ពិតជាត្រឹមត្រូវប្រាកដមែន ហើយអតិថិជនទទួលខុសត្រូវលើរាល់ការដាក់បញ្ជាតាមរយៈទូរស័ព្ទ និងអាសយដ្ឋានអ៊ីម៉ែល ។

៣.៧.៣ លោកអ្នក យល់ព្រមឱ្យក្រុមហ៊ុនថតសម្លេងទុកជាភស្តុតាងពេលអតិថិជនដាក់បញ្ជា ឬពេលក្រុមហ៊ុនជូនដំណឹងអំពីព័ត៌មាននៃការអនុវត្តបញ្ជាតាមរយៈការហៅទូរស័ព្ទ។

៣.៧.៤ លោកអ្នក ត្រូវជូនដំណឹងភ្លាមដល់ក្រុមហ៊ុនក្នុងករណីអតិថិជនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជា បានប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជា។

៣.៨ ការបដិសេធទទួលបញ្ជា

៣.៨.១ ក្រុមហ៊ុន មិនត្រូវអនុវត្តតាមបញ្ជាអតិថិជនទេ ប្រសិនបើការអនុវត្តបញ្ជាអតិថិជននោះផ្ទុយនឹងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ឬលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ ក្រុមហ៊ុនមិនទទួលខុសត្រូវលើការខាតបង់ថ្លៃដើម ឬការចំណាយរបស់អតិថិជនឡើយ ដែលបណ្តាលមកពីការបដិសេធរបស់ក្រុមហ៊ុនក្នុងការអនុវត្តតាមបញ្ជារបស់អតិថិជន។

៣.៨.២ ក្រុមហ៊ុន ត្រូវជូនដំណឹងភ្លាមៗដល់អតិថិជនជាលាយលក្ខណ៍អក្សរក្នុងករណីមានការបដិសេធដូចមានចែងក្នុងកថាខណ្ឌទីមួយ ឬមានកំហុសឆ្គងក្នុងការអនុវត្តបញ្ជារបស់អតិថិជន ឬការអនុវត្តបញ្ជាដោយអនុលោមតាមលក្ខខណ្ឌនៃបញ្ជាអតិថិជន។

៣.៩ ការជូនដំណឹងការជួញដូរមូលបត្របំណុលរដ្ឋ

៣.៩.១ ក្រុមហ៊ុនត្រូវជូនដំណឹងដល់អតិថិជននៅរាល់ប្រតិបត្តិការមូលបត្របំណុលរដ្ឋ ដែលធ្វើក្នុងនាមអតិថិជនដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ។ អតិថិជនយល់ព្រមពិនិត្យយ៉ាងយកចិត្តទុកដាក់នូវការជូនដំណឹងនោះ ហើយជូនដំណឹងទៅក្រុមហ៊ុនវិញភ្លាមនូវភាពខុសគ្នារវាងកំណត់ត្រារបស់អតិថិជន និងព័ត៌មានដែលបង្ហាញក្នុងសេចក្តីជូនដំណឹង។

៣.១០ របាយការណ៍

៣.១០.១ លោកអ្នកទទួលស្គាល់ថាលោកអ្នកនឹងទទួលបានរបាយការណ៍ជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនទាក់ទងនឹងការជួញដូរមូលបត្របំណុលរដ្ឋដូចខាងក្រោម៖

ក. សេចក្តីជូនដំណឹងស្តីអំពីការជួញដូរមូលបត្របំណុលរដ្ឋដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ

ខ. របាយការណ៍ប្រតិបត្តិការប្រចាំខែក្នុងគណនីអតិថិជនដោយអនុលោមតាមប្រការ ២២ នៅក្រោមក្រមសីលធម៌វិជ្ជាជីវៈ

គ. របាយការណ៍ពាក់ព័ន្ធនឹងប្រាក់អតិថិជនដោយអនុលោមតាមច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ

៣.១០.២ លោកអ្នកព្រមព្រៀងក្នុងការពិនិត្យយ៉ាងយកចិត្តទុកដាក់លើខ្លឹមសារនៃរបាយការណ៍ដែលផ្តល់ដោយក្រុមហ៊ុន ដើម្បីធានាថាខ្លឹមសារនៃរបាយការណ៍ដែលបានផ្តល់ឱ្យមានសង្គតិភាពនឹងកំណត់ត្រាផ្ទាល់ខ្លួន និងជូនដំណឹងដល់ក្រុមហ៊ុនភ្លាមនូវគ្រាដែលមានភាពខុសគ្នាណាមួយ។

៣.១១ លាភការ

៣.១១.១ ភាគីទាំងពីរទទួលស្គាល់ និងព្រមព្រៀងថា ការបង់លាភការឱ្យក្រុមហ៊ុនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានកំណត់តាមកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែក និងអាចប្រែប្រួលតាមការកំណត់របស់ន.ម.ក ។

៣.១១.២ ក្រុមហ៊ុន អាចធ្វើបច្ចុប្បន្នកម្មកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែក នៅពេលមានការផ្លាស់ប្តូរលាភការ និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវាល់ការផ្លាស់ប្តូរនោះ។ ដើម្បីឱ្យការដំឡើងលាភការដែលត្រូវបង់ដូចមានចែកក្នុងកិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តលុះត្រាតែកិច្ចព្រមព្រៀងនេះបានធ្វើបច្ចុប្បន្នកម្ម ហើយអតិថិជនបានជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងការយល់ព្រម។

៣.១១.៣ ក្រុមហ៊ុន ត្រូវព្រមព្រៀងថានៅពេលគិតថ្លៃសេវាពីអតិថិជនលើសចំនួនដែលមានចែកក្នុងកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែក ត្រូវបង្វិលប្រាក់ដែលបង់លើសចូលក្នុងគណនីសាច់ប្រាក់អតិថិជនវិញភ្លាមៗ និងត្រូវជូនដំណឹងជាលេងលាក់អក្សរដល់អតិថិជន។

៣.១២ ផលប្រយោជន៍ និងទំនាក់ទំនង

៣.១២.១ ក្រុមហ៊ុន ត្រូវបញ្ជាក់នូវាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ក្រុមហ៊ុន ឬក្នាក់ងារក្រុមហ៊ុនមូលបត្រក្នុងតារាង (២) ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

៣.១៣ ការតវ៉ា

៣.១៣.១ ករណីក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ ឬក្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរដោយត្រូវមានបញ្ជាក់ឈ្មោះនិងព័ត៌មានលម្អិតនៃបុគ្គលដោះស្រាយការតវ៉ារបស់ ក្រុមហ៊ុន។

៣.១៣.២ ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយវិវាទរបស់អតិថិជនក្នុងអំឡុងពេល ៧ ថ្ងៃនៅថ្ងៃធ្វើការបន្ទាប់ពីបានទទួលការតវ៉ា។

៣.១៣.៣ ក្នុងករណីដែលពាក្យបណ្តឹងមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃធ្វើការ ដោយសារភាពស្មុគស្មាញ ឬស្ថានការណ៍ផ្សេងទៀត ក្រុមហ៊ុននឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ លោកអ្នក អំពីមូលហេតុនៃការពន្យារពេល ស្ថានភាពនៃពាក្យបណ្តឹង និងរយៈពេលដែលរំពឹងទុកសម្រាប់ការដោះស្រាយ។ ក្រុមហ៊ុននឹងបន្តដោះស្រាយពាក្យបណ្តឹងនោះដោយឆាប់រហ័សនិងដោយសុចរិតភាព រហូតដល់មានការដោះស្រាយចុងក្រោយ។

៣.១៤ តំណាងរបស់អតិថិជន

៣.១៤.១ អតិថិជន អាចជ្រើសរើសបុគ្គលក្រៅពីក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រធ្វើជាតំណាង តាមរយៈលិខិតផ្ទេរសិទ្ធិ ឬការអនុញ្ញាតដោយច្បាប់ដើម្បីដាក់បញ្ជាទិញ-លក់ ឬបញ្ជាផ្សេងទៀតក្នុងនាមអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ នៅពេលចុះកិច្ចព្រមព្រៀងនេះអតិថិជនដែលមានបំណងជ្រើសរើសបុគ្គលដែលធ្វើជាអ្នកតំណាងត្រូវបញ្ជាក់ក្នុងកិច្ចព្រមព្រៀងអតិថិជនដាច់ដោយឡែក។

៣.១៤.២ មុនទទួលបញ្ជាពីអ្នកតំណាងរបស់អតិថិជន ក្រុមហ៊ុនត្រូវតម្រូវឱ្យអតិថិជនផ្តល់ឱ្យក្រុមហ៊ុននៅឯកសារដើម ឬថតចម្លង មានបញ្ជាក់ត្រឹមត្រូវនៃការអនុញ្ញាតនូវការជ្រើសរើសអ្នកដំណាង។

៣.១៤.៣លោកអ្នក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាម ដល់ក្រុមហ៊ុនពីការដកហូតសិទ្ធិរបស់អ្នកតំណាង។ ក្រុមហ៊ុនអាចធ្វើប្រតិបត្តិការដែលទទួលបានពីអ្នកតំណាង តាមបញ្ជាទិញលក់មូលបត្រ ឬបញ្ជាផ្សេងទៀតលើកលែងតែមានការជូនដំណឹងផ្សេងទៀតពីអតិថិជន។

៣.១៥ ការរក្សាភាពសម្ងាត់

៣.១៥.១ ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងការអនុវត្តសេវាកម្មស្របតាមកិច្ចព្រមព្រៀងនេះទៅឱ្យបុគ្គលណាផ្សេងឡើយ លើកលែងតែមានករណីណាមួយដូចខាងក្រោម៖

ក. មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលនូវព័ត៌មានសម្ងាត់។

ខ. មានការស្នើសុំពី ន.ម.ក ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

គ. មានការតម្រូវដោយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

៣.១៦ សេចក្តីថ្លែងព័ត៌មានហានិភ័យ

៣.១៦.១ អតិថិជនត្រូវទទួលស្គាល់ថាថ្លៃមូលបត្របំណុលរដ្ឋ អាចប្រែប្រួលឡើង ឬចុះ ហើយព័ត៌មានដែលត្រូវបានផ្តល់ឱ្យអំពីចំណូលនៃការវិនិយោគ ឬថ្លៃមូលបត្របំណុលរដ្ឋ ដែលស្របតាមកិច្ចព្រមព្រៀងនេះនិងមិនត្រូវបានធានាដោយក្រុមហ៊ុនឬ បុគ្គលផ្សេងទៀតឡើយ។

៣.១៦.២ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងសេចក្តីថ្លែងព័ត៌មានហានិភ័យផ្សេងទៀតដែលផ្អែកលើសេវាកម្មដែលបានផ្តល់ឱ្យប្រសិនបើមាន។

៣.១៧ ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង

៣.១៧.១ កិច្ចព្រមព្រៀងនេះត្រូវធ្វើជាពីរច្បាប់ដែលមានចុះហត្ថលេខា ឬស្នាមម្រាមដៃ និងត្រារបស់ក្រុមហ៊ុន របស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនត្រូវផ្តល់ឱ្យអតិថិជនមួយច្បាប់ភ្លាមៗនិងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

៣.១៨ បដិវាទកម្ម

៣.១៨.១ ដោយអនុលោមតាមប្រការ ៦ នៃក្រមសីលធម៌វិជ្ជាជីវៈ រាល់លក្ខខណ្ឌនៃកិច្ចព្រមព្រៀងមិនត្រូវលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយ ច្បាប់។ រាល់លក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះ និង/ឬកិច្ចព្រមព្រៀងផ្សេងទៀត រវាងភាគីទាំងពីរដែលលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់ មិនមានអានុភាពអនុវត្តឡើយ។

៣.១៩ ការជូនដំណឹង

៣.១៩.១ រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឱ្យអតិថិជន ត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬក្រុមសីលធម៌វិជ្ជាជីវៈ លើកលែងតែមានសំណើជាលាយលក្ខណ៍អក្សរផ្សេងពីនេះពីអតិថិជន។

៣.១៩.២ អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមៗមកដល់ក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាស័យដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។

៣.២០ ការបញ្ចប់កិច្ចសន្យា

៣.២០.១ ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ៧ ថ្ងៃដល់ភាគីម្ខាងទៀត។

៣.២០.២ ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗ ដែលមានមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ។

៣.២១ កិច្ចព្រមព្រៀងរួម

៣.២១.១ កិច្ចព្រមព្រៀងនេះជាកិច្ចព្រមព្រៀងរួមរវាងភាគីទាំងសងខាង ដែលចែកអំពីការតែងតាំងក្រុមហ៊ុនមូលបត្រធ្វើជាភ្នាក់ងាររបស់អតិថិជននិងលក្ខខណ្ឌនៃការផ្តល់សេវាកម្ម។ រាល់បទបង្ហាញ សេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀត ទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់ រវាង ភាគីទាំងសងខាងដែលពាក់ព័ន្ធនឹងបញ្ហានេះ មិនមានអនុភាពអនុវត្តឡើយ។

៣.២២ ការកែប្រែ

៣.២២.១ កិច្ចព្រមព្រៀងនេះអាចកែប្រែនៅពេលមានការយល់ព្រមរវាងភាគីទាំងសងខាង។ នៅពេលមានការធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនមូលបត្រត្រូវកែប្រែកិច្ចព្រមព្រៀងនេះឱ្យស្របតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលបានធ្វើវិសោធនកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឱ្យអតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ។

៣.២៣ ការចាត់តាំង

៣.២៣.១ លោកអ្នកព្រមព្រៀងថារាល់សិទ្ធិ និងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវផ្ទេរទៅឱ្យប្រតិសិទ្ធិសកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជនក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃមូលបត្រដែលកើតឡើងដោយប្រតិបត្តិការនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្សីយធន អសមត្ថភាព ដីការតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវចាត់ចែងនូវរាល់ការផ្ទេរមូលបត្របំណុលរដ្ឋ និងការចុះបញ្ជីនៃការផ្ទេរនោះ។

៣.២៤ ច្បាប់គ្រប់គ្រង និង យុត្តាធិការ

៣.២៤.១ កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៣.២៤.២ រាល់វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងនេះអាចដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទដែលកំណត់ដោយ ន.ម.ក.។

៣.២៤.៣ ប្រសិនបើវិវាទនោះមិនអាចដោះស្រាយបានតាមនីតិវិធីដែលកំណត់ដោយ ន.ម.ក ក្នុងរយៈពេលសមស្របទេ វិវាទនោះត្រូវដោះស្រាយជាចុងក្រោយតាមរយៈការអាជ្ញាកណ្តាល នៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា (NCAC) ស្របតាមវិធានអាជ្ញាកណ្តាលដែលមានសុពលភាពនៅពេលដាក់សំណើ។ សេចក្តីសម្រេចរបស់អាជ្ញាកណ្តាល គឺជាសេចក្តីសម្រេចចុងក្រោយ និងមានអនុភាពអនុវត្តលើភាគីទាំងអស់។

តារាង ក៖ និយមន័យ និងពាក្យកាត់

តារាង ខ៖ គោលការណ៍ឯកជនភាព

តារាង គន្ះ បញ្ជីឈ្មោះក្រុមហ៊ុន រ៉ូយ៉ាល់ក្រុប